ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍

OPEN ACCESS

ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម
Cambodian Journal of Education and STEM

អត្ថបទស្រាវជ្រាវ ( Original Article )

# ការយល់ឃើញរបស់សិស្សនៅលើការអនុវត្តកម្មសិក្សាគរុកោសល្យ របស់កម្មសិក្សាការី-ការិនី ឆ្នាំទី៤៖ ករណីសិក្សា វិទ្យាល័យទឹកល្អក់ និង វិទ្យាល័យជាស៊ីមសាមគ្គី រាជធានីភ្នំពេញ

## Students′ Perception on the Implementation of Pedagogical Practicum during Student Teachers′ Fourth Year of Training: A Case Study at Teuk Laak High School and Chea Sim Samaki High School, Phnom Penh

វង់ រ៉េន និងស្រៀង គីមស្រ៊ន
ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
*អ្នកនិពន្ធទទួលបន្ទុកឆ្លើយឆ្លង៖ vong.ren@ptec.edu.kh

Ren Vong * and Kimsron Srieng

Department of Science, Phnom Penh Teacher Education College, Phnom Penh, Cambodia

*Corresponding author: vong.ren@ptec.edu.kh

DOI:https://doi.org/10.62219/cjes.2026415

| ទទួលបានអត្ថបទ៖ ៣០ សីហា ២០២៣ | កែសម្រួល៖ ១៥ ធ្នូ ២០២៥ | យល់ព្រមឱ្យបោះពុម្ព៖ ១៥ មីនា ២០២៦ |
|---|---|---|
| **Received:** 30 August 2023 | **Revised:** 15 August 2025 | **Accepted:** 15 March 2026 |

**មូលន័យសង្ខេប**

ការសិក្សានេះមានគោលបំណង គឺដើម្បីស្វែងយល់ការយល់ឃើញរបស់សិស្សចំពោះការចុះកម្មសិក្សា គរុកោសល្យក្នុងអំឡុងពេលឆ្នាំទី៤ នៃកម្មសិក្សាការី-ការិនីនៃវិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូ។ ការស្រាវជ្រាវប្រើវិធីសាស្ត្រ ចម្រុះ ( mixed methods ) ជាមួយទំហំគំរូ ១៦៦ នាក់ ដែលបានជ្រើសរើសដោយប្រើរូបមន្ត Yamane ( 1967 ) នៅវិទ្យាល័យទឹកល្អក់ និងវិទ្យាល័យជាស៊ីម សាមគ្គី មានសិស្សថ្នាក់ទី៧ និងថ្នាក់ទី៨។ ការប្រមូលទិន្នន័យបរិមាណវិស័យ គឺប្រើកម្រងសំណួរស្ទង់មតិសិស្សមាត្រដ្ឋាន Likert 5កម្រិត និងទិន្នន័យគុណវិស័យប្រើប្រាស់ការសម្ភាសបែបពាក់កណ្ដាលរចនាសម្ព័ន្ធ ( semi-structured interview )។ ទិន្នន័យបរិមាណវិស័យ ពីការស្ទង់មតិបានវិភាគ ដោយប្រើកម្មវិធី IBM SPSS Statistics ( 2022 ) លើមធ្យម គម្លាតស្តង់ដារ និង t-test ចំណែកទិន្នន័យគុណវិស័យ ពីការសម្ភាសត្រូវបានវិភាគដោយយោងទៅតាមបរិបទស្ថានភាព។ លទ្ធផលបង្ហាញថា សិស្សមានការយល់ឃើញ វិជ្ជមានទូទៅចំពោះកម្មសិក្សាគរុកោសល្យ

របស់កម្មសិក្សាការី-ការិនី ដូចជាការជឿថា គ្រូបណ្តុះបណ្តាលមានចំណេះដឹងល្អ មានអាកប្បកិរិយាសមរម្យ និងស្ងប់ស្ងាត់ អនុវត្តវិធីសាស្ត្របង្រៀន និងរៀនយ៉ាងទូលំទូលាយ និងគ្រប់គ្រងថ្នាក់ បានមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងណា សិស្សមួយចំនួនក៏បានបង្ហាញការយល់ឃើញអវិជ្ជមានមួយចំនួនផង ដោយសម្គាល់ថា កម្មសិក្សាការី-ការិនីមានបទពិសោធន៍បង្រៀនកំណត់ និងមិនទាន់យល់ដឹងពេញលេញអំពីបរិបទ សិក្សារបស់សិស្សទាំងមូល។

**ពាក្យគន្លឹះ៖** ការយល់ឃើញ កម្មសិក្សាគរុកោសល្យ កម្មសិក្សាការី ការិនី

**Abstract**

This study aimed to explore students′ perceptions of the student teacher practicum during the fourth year of the teacher education college. The research used mixed methods with a sample size of 166 students selected using the Yamane (1967) formula at Tuek Laak High School and Chea Sim Samaki High School, who were in grades 7 and 8. Data were collected by means of a student survey using a 5-point Likert scale for quantitative data and a semi-structured interview for qualitative data. Quantitative data was analyzed using IBM SPSS Statistics (2022) to see Mean, SD, and t-test and then extract the qualitative data from the interviews and analyze them according to the situational context. The results showed that students had generally positive perceptions of the student teacher practicum, such as believing that the student teachers were knowledgeable, had a good attitude and calm, applied a wide range of teaching and learning methods, and managed the classroom effectively. However, some students also expressed some negative perceptions, noting that the student teacher practicum had limited teaching experience and did not fully understand the overall learning context of the students.

**Keywords:** Perception, Pedagogical Practicum, Student Teacher Practicum

## សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកំណែទម្រង់សំខាន់ៗលើវិស័យបណ្តុះបណ្តាលគ្រូ ដោយបង្កើត Teacher Education Colleges (TECs) និងពង្រឹងកម្មវិធីបណ្តុះបណ្តាលគ្រូតាមស្តង់ដារថ្មី ដើម្បីលើកកម្ពស់គុណភាពគ្រូបង្រៀន។ ការអនុវត្តគរុកោសល្យត្រូវបានបញ្ចូលជាសមាសធាតុស្នូលមួយនៃកម្មវិធីបណ្តុះបណ្តាល ដែលអនុញ្ញាតឱ្យគរុសិស្ស គរុនិស្សិត ចុះអនុវត្តការបង្រៀននៅសាលាគោលដៅក្រោមការត្រួតពិនិត្យរបស់គ្រូណែនាំ និងគ្រូបណ្តុះបណ្តាល (MoEYS, 2010)។

ទន្ទឹមនឹងនេះការបណ្តុះបណ្តាល គ្រូបង្រៀនត្រូវបានយកចិត្តទុកដាក់ពង្រឹងគុណភាពការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពនៅតាមសាលាគរុកោសល្យ និងវិក្រឹត្តការរាជធានីខេត្ត (Em et al., 2022) ។ គ្រូបង្រៀនត្រូវបំពេញកាតព្វកិច្ចក្នុងការសិក្សារៀនសូត្រយ៉ាងខ្ជាប់ខ្ជួន ដើម្បីបំពេញបន្ថែមលើជំនាញ មុខវិជ្ជាឯកទេស របស់ខ្លួនឱ្យបាន

ច្បាស់លាស់ ( MoEYS, 2021 )។ ដូចនេះ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន តម្រូវឱ្យមានការចុះអនុវត្តកម្មសិក្សាគរុកោសល្យ ដែលជាការអនុវត្តបង្រៀនសាកល្បងផ្ទាល់ដើម្បីឱ្យគរុសិស្ស គរុនិស្សិត ស្វែងរកនូវចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អ ( Lobo, 2022 )។

កម្មសិក្សាគរុកោសល្យ គឺជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ដែលផ្តល់ឱកាសឱ្យកម្មសិក្សាការី ការិនី ចូលរួមអនុវត្តការបង្រៀន និងកិច្ចការដែលពាក់ព័ន្ធនឹងវិស័យអប់រំជាក់ស្តែង ដើម្បីទទួលបានបទពិសោធន៍វិជ្ជាជីវៈក្នុងការបង្រៀន ( Lei & Yin, 2019 )។ ដោយការចូលរួមនេះត្រូវបានរៀបចំជាកម្មវិធីដែលផ្តល់ឱកាសឱ្យកម្មសិក្សាការី ការិនី ទទួលបានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីពការងារនៅវិស័យអប់រំកម្រិតបរិញ្ញាបត្រ តាមរយៈការចូលរួមក្នុងសកម្មភាពការងារដែលបានរៀបចំជាមុន និងស្ថិតក្រោមការត្រួតពិនិត្យយ៉ាងល្អិតល្អន់ ( Adebakin, 2015 ) ហើយមានតួនាទីជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងទំនួលខុសត្រូវ ព្រមទាំងជួយលើកកម្ពស់ និងផ្លាស់ប្តូរឥរិយាបថផ្ទាល់ខ្លួនរបស់កម្មសិក្សាការី ការិនី ( Margetts & Ure, 2007 )។

សមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន ត្រូវបានកំណត់ដោយធាតុសំខាន់ចំនួនបួន រួមមាន ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ ការស្រាវជ្រាវជាច្រើនបានបង្ហាញថា សមត្ថភាពវិជ្ជាជីវៈរបស់គ្រូមានទំនាក់ទំនងជាវិជ្ជមានជាមួយគុណភាពនៃការបង្រៀន និងសមិទ្ធផលសិក្សារបស់សិស្ស ( Hattie, 2009 )។ ចំណេះដឹងវិជ្ជាជីវៈសំដៅលើចំណេះដឹងអំពីខ្លឹមសារមេរៀន ចំណេះដឹងទូទៅ និងចំណេះដឹងអំពីសិស្ស ដែលជាមូលដ្ឋានសម្រាប់ការរៀបចំ និងការអនុវត្តការបង្រៀនឱ្យមានប្រសិទ្ធភាព ( Vygotsky, 1978; OECD, 2019 )។ Shulman ( 1986 ) បានបញ្ជាក់ថា គ្រូដែលមានចំណេះដឹងជ្រៅជ្រះលើខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀន អាចជួយឱ្យសិស្សយល់ដឹងបានកាន់តែប្រសើរ។

ការប្រតិបត្តិវិជ្ជាជីវៈ ផ្តោតលើការគ្រប់គ្រងបរិស្ថានសិក្សា និងការប្រើប្រាស់វិធីសាស្ត្របង្រៀនសមស្រប ដើម្បីលើកកម្ពស់ការចូលរួម និងសមិទ្ធផលសិក្សារបស់សិស្ស ( Hattie, 2009 )។ Marzano et al. ( 2003 ) បានរកឃើញថា ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពអាចបង្កើនការចូលរួមរបស់សិស្ស និងលទ្ធផលសិក្សាយ៉ាងល្អ។ រីឯការសិក្សាវិជ្ជាជីវៈ សំដៅលើការអភិវឌ្ឍបំណិនក្នុងការទំនាក់ទំនង និងបំណិនក្នុងការបង្រៀនតាមរយៈការសិក្សារៀនសូត្រជាបន្តបន្ទាប់ ការឆ្លុះបញ្ចាំងលើការអនុវត្ត និងការចែករំលែកបទពិសោធន៍វិជ្ជាជីវៈ ( Fullan, 2007; Schön, 1983 )។ Schön ( 1983 ) បានបង្ហាញថា ការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់របស់គ្រូអាចធ្វើឱ្យប្រសើរឡើងទាំងគុណភាពការបង្រៀន និងសមិទ្ធផលសិក្សារបស់សិស្ស។

លើសពីនេះ សីលធម៌វិជ្ជាជីវៈ គឺជាគុណតម្លៃដែលគ្រូត្រូវប្រកាន់ខ្ជាប់ ដោយរួមមានការយកចិត្តទុកដាក់ចំពោះសិស្ស អាកប្បកិរិយាវិជ្ជមាន ភាពយុត្តិធម៌ និងតម្លាភាពក្នុងការបំពេញភារកិច្ច ព្រមទាំងការគោរពពេលវេលា ដែលជាកត្តាសំខាន់ក្នុងការកសាងទំនុកចិត្ត និងលើកកម្ពស់គុណភាពអប់រំ ( UNESCO, 2015; OECD, 2019 )។ UNESCO ( 2015 ) បានអះអាងថា ការប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈរបស់គ្រូ គឺជាមូលដ្ឋានសម្រាប់ការផ្តល់ការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងគុណភាព។

ក្នុងន័យនេះ កម្មសិក្សាការី ការិនី ត្រូវបានចាត់ទុកថាជាបុគ្គលិកហាត់ការ ដែលចូលរួមក្នុងកិច្ចការអប់រំជាក់ស្តែង និងជាមធ្យោបាយសំខាន់សម្រាប់អ្នកអប់រំនាពេលអនាគត ក្នុងការទទួលបានបទពិសោធន៍ធ្វើការជាមួយសិស្ស ការគ្រប់គ្រងថ្នាក់រៀន ការអនុវត្តតាមគោលការណ៍ណែនាំ និងការទទួលបានការណែនាំពីអ្នកជំនាញក្នុងវិស័យអប់រំ ( Smith &

Souviney, 1997)។ ដូចនេះ ការអនុវត្តកម្មសិក្សាគរុកោសល្យរបស់កម្មសិក្សាការី ការិនី មានសារៈសំខាន់យ៉ាងខ្លាំង និងទាមទារឱ្យមានការយកចិត្តទុកដាក់ និងការគាំទ្រពីស្ថាប័នដែលពាក់ព័ន្ធ លោកគ្រូ លោកគ្រូ អ្នកគ្រូឧទ្ទេស ដឹកនាំ និងណែនាំសិស្ស និស្សិត ព្រមទាំងកម្មសិក្សាការី ការិនីផ្ទាល់ (Wasonga & Murphy, 2006) ។

គោលបំណងនៃកម្មសិក្សាគរុកោសល្យ គឺដើម្បីជំរុញឱ្យកម្មសិក្សាការី ការិនី ពិចារណាអំពីតួនាទីនៃការបង្រៀន និងរៀបចំពង្រឹងចំណេះដឹងឯកទេសរបស់ខ្លួន (Sharzadin et al., 2019)។ ការសិក្សាមួយបានបង្ហាញថា កម្មវិធីនេះមានតួនាទីសំខាន់ក្នុងការពង្រឹងចំណេះដឹង និងជំនាញបង្រៀនរបស់កម្មសិក្សាការី និងកម្មសិក្សាការិនី មុនពេលពួកគេចូលទៅបំពេញការងារជាក់ស្តែងក្នុងវិស័យអប់រំ (Afornyo, 2018)។

តាម Parveen & Mirza (2012) ការចុះកម្មសិក្សាមានសារៈសំខាន់ក្នុងការរៀបចំកម្មសិក្សាការី និងកម្មសិក្សាការិនីប្រកបដោយវិជ្ជាជីវៈ។ វាអនុញ្ញាតឱ្យពួកគេយល់ដឹងអំពីគោលដៅវិជ្ជាជីវៈ និងលក្ខខណ្ឌការងារពិតប្រាកដ ទទួលបានបទពិសោធន៍ជាក់ស្តែងលើការងារ អភិវឌ្ឍជំនាញវិជ្ជាជីវៈ និងអាកប្បកិរិយា និងបង្កើតបណ្តាញទំនាក់ទំនងដែលមានប្រយោជន៍ជាមួយមនុស្សដែលធ្វើការនៅក្នុងអាជីពដូចគ្នា។

**ការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនី**

តាមការសិក្សារបស់ Turman & Schrodt (2006) បានបង្ហាញពីការយល់ឃើញរបស់សិស្សទៅលើ ការឆ្លើយសំណួររបស់សិស្ស ទម្រង់នៃការបង្រៀន និងការប្រើប្រាស់អំណាចក្នុងការបង្រៀនរបស់គ្រូ។ ដោយឡែកនៅវិទ្យាល័យ Midwestern ក្នុងសហរដ្ឋអាមេរិក (United States) បានរកឃើញថា គ្រូមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសិស្ស តាមរយៈការប្រើប្រាស់ទម្រង់បង្រៀន និងការប្រើប្រាស់អំណាច ឥរិយាបថក្នុងការបង្រៀនដោយផ្តោតលើការលើកទឹកចិត្តជាចម្បង ជាជម្រើសល្អជាងការប្រើអំណាចហិង្សាដែលធ្វើឱ្យបរិយាកាសល្អ (Schambach & Dirks, 2002)។ ស្របជាមួយគ្នានេះដែរ ការសិក្សារបស់ Bakx et al. (2015) បង្ហាញការយល់ឃើញរបស់សិស្សអំពីវិធីសាស្ត្រ របស់គ្រូបង្រៀនមានគុណភាព និងមានភាពទូលំទូលាយ។ ទន្ទឹមនឹងនោះ ការយល់ឃើញរបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិបង្ហាញថា បរិយាកាសសិក្សារបស់គ្រូបង្រៀន គឺបង្ហាញពីទំនាក់ទំនងខ្ពស់បំផុតជាមួយសមិទ្ធផលរបស់សិស្សក្នុងការសិក្សា ដែលមានន័យថា គ្រូបង្រៀន ឬកម្មសិក្សាការី ការិនីគ្រប់គ្រងបរិយាកាសសិក្សាបានល្អ ជាកត្តាមួយដែលអាចនាំឱ្យសិស្សទទួលបានលទ្ធផលខ្ពស់ក្នុងការសិក្សា (Akram, 2019)។

**បញ្ហាប្រឈមរបស់កម្មសិក្សាការី ការិនី**

ការអនុវត្តកម្មសិក្សាគរុកោសល្យរបស់កម្មសិក្សាការី ការិនីបានជួបប្រទះបញ្ហាប្រឈមមួយចំនួនផងដែរ។ ការសិក្សា Dos Santos (2020) បង្ហាញថា សិស្សបង្ហាញអាកប្បកិរិយាអវិជ្ជមាន ការមិនគោរពវិន័យ មិនយកចិត្តទុកដាក់ ក្នុងការសិក្សាជាមួយកម្មសិក្សាការី ការិនី។ Rodriguez et al. (2019) បន្ថែមថា ការយល់ឃើញរបស់សិស្សលើកម្មសិក្សាការី ការិនី ដែលមានប្រសិទ្ធភាពក្នុងការអនុវត្តស្តង់ដារវិជ្ជាជីវៈ ដោយពួកគេយល់ថានៅមានចំនុចខ្វះខាតដូចជា គ្រូមិនដឹងពីរបៀបរៀន របៀបពន្យល់ របៀបបំផុសគំនិត របៀបបង្កើតបរិយាកាសឱ្យសិស្សគិត និងរបៀបអនុវត្តន៍វិធីសាស្ត្រផ្សេងៗ។ អំឡុងពេលអនុវត្តការបង្រៀនមានមតិកែលម្អតាមរយៈការយល់ឃើញរបស់សិស្ស ទៅលើការចុះកម្មសិក្សារបស់គរុនិស្សិត ដូចជា ចំពោះ បរិយាកាសបង្រៀន ការផ្ទេរចំណេះដឹងទូទៅ របស់កម្មសិក្សាការី ការិនីនៅមានកម្រិត ដោយបង្ហាញថា ពួកគេអសមត្ថភាពក្នុងការប្រាស្រ័យទាក់ទង អសមត្ថភាពក្នុងការសម្របសម្រួល និងការខ្វះចំណេះដឹងទៅលើខ្លឹមសារមេរៀន

ដែលនាំឱ្យការរំពឹងទុកមិនទទួលបានប្រសិទ្ធភាព ហើយការចូលរួមរបស់សិស្សទាំងអស់ មិនសកម្ម (Keshmiri et al., 2018)។ បន្ថែមពីនេះការសិក្សាបង្ហាញថា កម្មសិក្សាការី ការិនី មានបទពិសោធន៍តិចក្នុងការបង្រៀន និងការអនុវត្តវិធីសាស្ត្របង្រៀនមានលក្ខណៈស្មុគស្មាញ (Kagoda & Sentongo, 2015)។ តាមរយៈការស្រាវជ្រាវ Panda &Nayak (2014) បានបង្ហាញថា កម្មសិក្សាការី ការិនីប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនក្នុងអំឡុងពេលចុះបង្រៀន ដូចជា ការរក្សាវិន័យក្នុងថ្នាក់ ការគ្រប់គ្រងសិស្ស ការពន្យល់មេរៀន ការគ្រប់គ្រងពេលវេលា និងការជ្រើសរើសវិធីសាស្ត្រសមស្របក្នុងការបង្រៀន។ បញ្ហាទាំងនេះអាចបង្កឱ្យមានភាពលំបាកក្នុងការអនុវត្តកម្មសិក្សាឱ្យប្រសិទ្ធភាព។ ដោយផ្អែកលើការចុះកម្មសិក្សាគរុកោសល្យឆ្នាំទី៣ ចំនួន ៥ សប្តាហ៍នៅមណ្ឌលកម្មសិក្សា ក្នុងអំឡុងអនុវត្តកម្មសិក្សាគរុកោសល្យ ដោយសារកម្មសិក្សាការី ការិនីស្ថិតក្នុងស្ថានភាពផ្សេងៗគ្នាបែបនេះ និងមានបញ្ហាប្រឈមខ្លះដូចទៅនឹងការសិក្សាខាងលើនេះ ទើបអ្នកស្រាវជ្រាវលើកយកប្រធានបទនេះឡើងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ ការស្រាវជ្រាវនេះមានគោលបំណង ស្វែងយល់ទៅលើការយល់ឃើញរបស់សិស្សទៅលើការអនុវត្តកម្មសិក្សាគរុកោសល្យរបស់កម្មសិក្សាការី ការិនីឆ្នាំទី៤។

ក្នុងន័យនេះអ្នកស្រាវជ្រាវបានធ្វើសំយោគខ្លឹមសារខាងលើផ្តោតសំខាន់លើលទ្ធផលសិក្សាដែលមានការលើកឡើងអថេរចំនួន៤ សំខាន់ៗ នឹងសូចនាករមួយចំនួនមកធ្វើការបកស្រាយលំអិតទៅលើសាលាគោលដៅនៃកម្មសិក្សានោះគឺៈ **ចំណេះដឹងវិជ្ជាជីវៈ** *(ចំណេះដឹងអំពីខ្លឹមសារមេរៀន ចំណេះដឹងទូទៅ និងចំណេះដឹងអំពីសិស្ស)* **ការប្រតិបត្តិវិជ្ជាជីវៈ** *(ការគ្រប់គ្រងបរិស្ថានសិក្សា និងវិធីសាស្ត្របង្រៀន)* **ការសិក្សាវិជ្ជាជីវៈ** *(បំណិនក្នុងការទំនាក់ទំនង និងបំណិនក្នុងការបង្រៀន)* និង**សីលធម៌វិជ្ជាជីវៈ** *(ការយកចិត្តទុកដាក់ អាកប្បកិរិយាវិជ្ជមាន ភាពយុត្តិធម៌ និងតម្លាភាព និងការគោរពពេលវេលា )* (MoEYS, 2024; OECD, 2019; UNESCO, 2015) ។

## វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធាននេះ បានប្រើវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ (Bressler & Bodzin, 2013) ។ ការសិក្សាបានធ្វើឡើងនៅក្នុងរាជធានីភ្នំពេញដោយជ្រើសរើសវិទ្យាល័យចំនួនពីរមកធ្វើការសិក្សាស្រាវជ្រាវ រួមមានវិទ្យាល័យ ជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់ ព្រោះសាលាទាំងនេះជាសាលាគោលដៅក្នុងការអនុវត្តកម្មសិក្សាគរុកោសល្យរបស់គរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដោយយោងតាមលិខិតឧទ្ទេសនាមលេខ០១១ វគគ.ឧទន។ ការសិក្សានេះជ្រើសរើសយកតែលើកម្រិតថ្នាក់ទី៧ និងទី៨ ដែលជាថ្នាក់អនុវត្តកម្មសិក្សាគរុកោសល្យក្នុងឆ្នាំ ២០២៣ ដោយមានសំណុំសាកល (Population size) នៃវិទ្យាល័យទាំងពីរមានចំនួន ៨៩៥ នាក់ ក្នុងឆ្នាំសិក្សា២០២២-២០២៣ (តារាងទី១)។

តារាងទី១៖ *សំណាកចូលរួមស្រាវជ្រាវ*

| សាលារៀន | កម្រិតថ្នាក់ទី៧ | ចំនួន | កម្រិតថ្នាក់ទី៨ | ចំនួន | សំណាកសរុប |
|---|---|---|---|---|---|
| វិទ្យាល័យជាស៊ីមសាមគ្គី | ៨ថ្នាក់ | ៣៧១នាក់ | ៩ថ្នាក់ | ៣៨៥នាក់ | ៧៥៦ |
| វិទ្យាល័យទឹកល្អក់ | ៣ថ្នាក់ | ៦៥នាក់ | ៣ថ្នាក់ | ៧៤នាក់ | ១៣៩ |
| សរុប | ១១ថ្នាក់ | ៤៣៦នាក់ | ១២ថ្នាក់ | ៤៥៩ | ៨៩៥ |

សំណាកស្រាវជ្រាវនៃការសិក្សានេះត្រូវបានជ្រើសរើសដោយប្រើរូបមន្តរបស់ Yamane (1967, as cited in Umar & Wachiko, 2021) ដោយគណនាយក ៧% នៃកម្រិតលំអៀងនៃចំនួនសិស្សដែលត្រូវចូលរួម។ តាមលទ្ធផលនៃ

ការគណនាបានចំនួនសំណាក មានសិស្សចំនួន ១៦៦ នាក់ដែលត្រូវចូលរួមក្នុងការស្ទង់មតិ។ រូបមន្តនៃការគណនាជ្រើសរើសសំណាកស្រាវជ្រាវ មានបង្ហាញដូចខាងក្រោម៖

$$n = \frac{N}{1+N(e)^2} = \frac{895}{1+895(0.07)^2} = 166$$

n: តំណាងគំរូ , N: សកលគំរូ , e : កម្រិតនៃភាពលំអៀង

តារាងទី២៖ *ចំនួនសំណាកគំរូ*

| ល.រ | ទីកន្លែងសិក្សា | សិស្សសរុប (នាក់) | តំណាងគំរូ (នាក់) | % នៃចំនួនសិស្សចូលរួម |
|---|---|---|---|---|
| 1 | វិទ្យាល័យជាស៊ីមសាមគ្គី | 756 | 140 | 18% |
| 2 | វិទ្យាល័យទឹកល្អក់ | 139 | 26 | 18% |
| | **សរុប** | **166 នាក់** | | |

ការស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានប្រើប្រាស់ កម្រងសំណួរស្ទង់មតិសម្រាប់ប្រមូលទិន្នន័យបែបបរិមាណវិស័យ (Onwuegbuzie et al., 2010) និងសំណួរសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធ សម្រាប់ទិន្នន័យបែបគុណវិស័យពីសិស្ស (Attride-Stirling, 2001)។ សម្រាប់សំណាកស្រាវជ្រាវដែលជ្រើសរើសសម្រាប់ការសម្ភាសស៊ីជម្រៅគឺមានចំនួន ៤នាក់ (ស្រី ២នាក់) ដែលតំណាងទីកន្លែងសិក្សាទាំងពីរ។ អ្នកស្រាវជ្រាវជ្រើសយកសំណាកសម្ភាស មួយសាលាគោលដៅចំនួន ២ នាក់ ដោយសារពួកគាត់ជាអ្នកធ្លាប់រៀនជាមួយគ្រូចុះកម្មសិក្សាបានច្រើនឆ្នាំ ដូចនេះគាត់មានព័ត៌មានច្រើនអំពីគ្រូចុះកម្មសិក្សា ដែលជាចម្លើយត្រឹមត្រូវមិនលំអៀង។ ក្រុមគោលដៅទាំង៤នាក់នោះ ជាសិស្សដែលមានបទពិសោធន៍ច្រើនក្នុងការរៀនជាមួយកម្មសិក្សាការី ការិនីពីមុនមក។ ដូចនេះ ពួកគេអាចផ្ដល់ព័ត៌មានបានជាក់លាក់ និងច្បាស់លាស់អំពីស្ថានភាពកម្មសិក្សាការី ការិនីដែលបានអនុវត្តកម្មសិក្សាគរុកោសល្យកន្លងមក។ ព័ត៌មានអំពីសិស្សចូលរួមក្នុងការសម្ភាស មានបង្ហាញក្នុងតារាងទី២។

តារាងទី៣៖ *ព័ត៌មានអំពីសិស្សចូលរួមក្នុងការសម្ភាស*

| លេខកូដ | ភេទ | ថ្នាក់ | អាយុ (ឆ្នាំ) | សាលារៀន | បទពិសោធរៀនជាមួយកម្មសិក្សាការី ការិនី (ឆ្នាំ) |
|---|---|---|---|---|---|
| សិស្សទី១ | ស្រី | ៧ | ១២ | វិទ្យាល័យជាស៊ីមសាមគ្គី | ១ |
| សិស្សទី២ | ប្រុស | ៨ | ១៣ | វិទ្យាល័យជាស៊ីមសាមគ្គី | ៣ |
| សិស្សទី៣ | ប្រុស | ៧ | ១២ | វិទ្យាល័យទឹកល្អក់ | ១ |
| សិស្សទី៤ | ស្រី | ៨ | ១៣ | វិទ្យាល័យទឹកល្អក់ | ២ |

តារាងទី២ ពណ៌នាអំពីព័ត៌មានរបស់សិស្សទាំង៤នាក់ដែលចូលរួមការសម្ភាសដោយប្រើប្រាស់កម្រងសំណួរសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធ។ ដូចបង្ហាញក្នុងតារាងទី២ មានសិស្សថ្នាក់ទី៧ ចំនួន២នាក់ និងសិស្សថ្នាក់ទី៨ ចំនួន២នាក់មកពីវិទ្យាល័យជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់ដែលត្រូវបានសម្ភាស។ ពួកគេមានអាយុ១២ និង១៣ឆ្នាំ និងធ្លាប់មានបទពិសោធសិក្សារៀនសូត្រជាមួយកម្មសិក្សាការី ការិនី ចំនួនពី១ឆ្នាំ ទៅ៣ឆ្នាំ។

**ឧបករណ៍ប្រមូលទិន្នន័យ**

ការស្រាវជ្រាវនេះបានប្រើប្រាស់ កម្រងសំណួរស្ទង់មតិតាមមាត្រដ្ឋាន Likert មាន៥កម្រិត (១. មិនយល់ស្របខ្លាំង ២. មិនយល់ស្រប ៣. ធម្មតា ៤. យល់ស្រប និង ៥. យល់ស្របខ្លាំង) សម្រាប់ប្រមូលទិន្នន័យបែបបរិមាណវិស័យ (Onwuegbuzie et al., 2010) ផ្ដោតទៅលើលទ្ធផលដែលមានកម្រងសំណួរស្ទង់មតិផ្ដោតលើស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន (MoEYS, 2010; Sørensen et al., 1996)។ តាមបែបគុណវិស័យ ដែលផ្ដើមចេញពីលទ្ធផលខាងលើឱ្យកាន់តែស៊ីជម្រៅ ក្នុងនោះគឺ សម្រាប់សំណួសម្ភាសពាក់កណ្ដាលរចនាសម្ព័ន បានរៀបចំដោយផ្ដោតលើគោលបំណងនៃការស្រាវជ្រាវដែលបំបែកចេញជាសំណួរតូចៗមួយចំនួនសម្រាប់សួរដេញដោលទៅកាន់អ្នកចូលរួមសម្ភាសទាំងបួននាក់ (Attride, 2001)។

**នីតិវិធីប្រមូលទិន្នន័យ**

អ្នកស្រាវជ្រាវបែងចែកការប្រមូលទិន្នន័យជាពីរប្រភេទគឺ ប្រភេទទិន្នន័យចម្បង និង ប្រភេទទិន្នន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បង គឺជាទិន្នន័យដែលអ្នកស្រាវជ្រាវចុះទៅយកផ្ទាល់តាមរយៈ កម្រងសំណួរស្ទង់មតិដោយផ្ដោតលើ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនផ្ទាល់ពីសិស្ស (Wagh, 2021) ដែលរៀននៅវិទ្យាល័យជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់។ ។ ទិន្នន័យបន្ទាប់បន្សំគឺបានមកពីក្រសួងអប់រំ យុវជន និងកីឡា អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ ទស្សនាវដ្ដីវិទ្យាសាស្ត្រ ដែលផ្ដោតទៅលើស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន(Sørensen et al., 1996)។

ចំពោះការសម្ភាសបែបស៊ីជម្រៅ (in-depth interview) អ្នកស្រាវជ្រាវបានប្រើសំណួរសម្ភាសពាក់កណ្ដាលរចនាសម្ព័ន ដោយផ្ដោតលើគោលបំណងនៃការស្រាវជ្រាវដែលបំបែកចេញជាសំណួរតូចៗ សម្រាប់សួរដេញដោលទៅកាន់អ្នកចូលរួមសម្ភាសទាំងបួននាក់ នៅសាលាគោលដៅដោយផ្ទាល់។ ទិន្នន័យនៃការសម្ភាសត្រូវបានកត់ត្រា និងថតសំឡេង (voice recorded) ដែលបានអនុញ្ញាតពីអ្នកចូលរួមយ៉ាងត្រឹមត្រូវ។ ការប្រមូលទិន្នន័យតាមរយៈការស្ទង់មតិ និងការសម្ភាសស៊ីជម្រៅនេះ បានធ្វើឡើងនៅសប្ដាហ៍ទី១០ ខែមីនា ឆ្នាំ២០២៣ ដែលជាសប្ដាហ៍ចុងក្រោយនៃការអនុវត្តកម្មសិក្សាគរុកោសល្យរបស់កម្មសិក្សាការី ការិនី។

**ការវិភាគទិន្នន័យ**

បន្ទាប់ពីបានប្រមូលទិន្នន័យរួចរាល់ អ្នកស្រាវជ្រាវបានយកទិន្នន័យបែបបរិមាណវិស័យមកវិភាគយ៉ាងល្អិតល្អន់ តាមរយៈកម្មវិធី SPSS 2022 (Version 22)។ ការវិភាគលទ្ធផលនៃការស្រាវជ្រាវនេះបានអនុវត្តតាម Fisher & Marshall (2009) និង Houn & Em (2022) ដោយផ្ដោតលើស្ថិតិសន្និដ្ឋាន (inferential statistics) និងវិភាគតាម Independent sample t-test ដើម្បីបង្ហាញលទ្ធផលស្រាវជ្រាវរវាងសិស្សនៅវិទ្យាល័យទឹកល្អក់ និងសិស្សនៅវិទ្យាល័យជាស៊ីមសាមគ្គីដោយផ្អែកតាមលក្ខខណ្ឌស្ថិតិក្នុងគំរូស្រាវជ្រាវ។ ក្នុងនោះដែរ អ្នកស្រាវជ្រាវបានប្រើប្រាស់សន្ទស្សន៍តម្លៃមធ្យម (WAI: Weight Average Index) សម្រាប់វិភាគដើម្បីសិក្សាស្វែងរកគំនិតយល់ឃើញជារួមរបស់សិស្សលើប្រភេទប្រយោគកម្រិតមាត្រដ្ឋាន Likert (Sok et al., 2021)។ សន្ទស្សន៍តម្លៃមធ្យម៥កម្រិត ដែលបានកំណត់នោះ គឺ មិនយល់ស្របខ្លាំង = 0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, និងយល់ស្របខ្លាំង = 0.81-1.00។ សន្ទស្សន៍តម្លៃមធ្យម (WAI ) ត្រូវបានគណនាចេញពីតម្លៃមាត្រដ្ឋាន Likert 5 កម្រិត ដោយសន្ទស្សន៍តម្លៃធំបំផុតគឺ 1.00 ហើយតូចបំផុតគឺ 0.00 ដោយយកតម្លៃ 1 (តម្លៃខ្ពស់បំផុតនៃសន្ទស្សន៍) ចែកជាមួយ 5 កម្រិត (សូមមើល Sok et al., 2021)។

ចំពោះទិន្នន័យបែបគុណវិស័យ អ្នកស្រាវជ្រាវបានវិភាគតាមវិធីសាស្ត្រវិភាគរកប្រធានបទ (thematic analysis) ដោយផ្តោតអថេរចំនួន៤ សំខាន់៖១.លើចំណេះដឹងវិជ្ជាជីវៈដែលមានសូចនាករ ចំណេះដឹងអំពីខ្លឹមសារមេរៀន ចំណេះដឹងទូទៅ និងចំណេះដឹងអំពីសិស្ស, ២.ការប្រតិបត្តិវិជ្ជាជីវៈ ដែលមានសូចនាករ ការគ្រប់គ្រងបរិស្ថានសិក្សា និងវិធីសាស្ត្របង្រៀន ៣.ការសិក្សាវិជ្ជាជីវៈដែលមានសូចនាករ បំណិនក្នុងការទំនាក់ទំនង និងបំណិនក្នុងការបង្រៀន និង៤.សីលធម៌វិជ្ជាជីវៈដែលមានសូចនាករ ការយកចិត្តទុកដាក់ អាកប្បកិរិយាវិជ្ជមាន ភាពយុត្តិធម៌ និងតម្លាភាព និងការគោរពពេលវេលា ។ ព័ត៌មានដែលបានកត់ត្រា និងសំលេង ត្រូវបានយកមកសរសេរជាអក្សរ (transcribe) រួចចាប់ផ្តើមវិភាគតាមប្រធានបទដែលអ្នកស្រាវជ្រាវចង់បាន (Terry et al., 2017)។ ក្នុងដំណើរការនេះ អ្នកស្រាវជ្រាវក៏បានគោរពគោលការណ៍សីលធម៌ស្រាវជ្រាវ ដោយធានាការយល់ព្រមដោយស្ម័គ្រចិត្ត (Informed Consent) របស់អ្នកចូលរួម ការរក្សាការសម្ងាត់នៃទិន្នន័យ និងការការពារអត្តសញ្ញាណអ្នកចូលរួមតាមរយៈការប្រើលេខកូដ ឬពាក្យជំនួសឈ្មោះពិត ដើម្បីធានាសិទ្ធិ ឯកជនភាព និងសុវត្ថិភាពរបស់អ្នកចូលរួមពេញមួយដំណើរការស្រាវជ្រាវ (Orb et al., 2001)។

### សីលធម៌នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវយល់ច្បាស់ពីក្រមសីលធម៌ស្តីពីការស្រាវជ្រាវដោយមានលិខិតចាត់តាំងពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដូចជាលិខិតឧទ្ទេសនាមដើម្បីចុះធ្វើកម្មសិក្សាគរុកោសល្យ និងលិខិតស្នើសុំចុះប្រមូលទិន្នន័យស្រាវជ្រាវ។ ការស្រាវជ្រាវនេះបានទទួលការអនុញ្ញាតពីគណៈគ្រប់គ្រងពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដើម្បីស្នើសុំចុះស្រាវជ្រាវ និងលិខិតអនុញ្ញាតប្រមូលទិន្នន័យពីវិទ្យាល័យទាំងពីរផងដែរ។ ក្នុងនាមជាអ្នកស្រាវជ្រាវ ដើម្បីឱ្យការសិក្សានេះធានាបាននូវភាពជឿជាក់(Reliability) និងមានសុពលភាព(Validity) សំខាន់នោះគឺការគោរព ការប្រកាន់យកនូវគោលការណ៍ក្រមសីលធម៌មួយចំនួនដូចជា មានភាពស្មោះត្រង់ក្នុងការទំនាក់ទំនង ទំនួលខុសត្រូវ ជឿទុកចិត្តក្នុងការអនុវត្តការស្រាវជ្រាវ និងសត្យានុម័ត (មានការវិភាគបានគ្រប់ជ្រុងជ្រោយ)។ អ្នកស្រាវជ្រាវផ្តល់សិទ្ធដល់អ្នកចូលរួមក្នុងការផ្តល់បទសម្ភាសដោយ ត្រូវណែនាំខ្លួន និងបង្ហាញពីគោលបំណងនៃការស្រាវជ្រាវរបស់អ្នកសិក្សា បន្ទាប់មកត្រូវពិនិត្យ និងសុំការអនុញ្ញាត្តិពីការចូលរួម ហើយអ្នកចូលរួមមានការសម្រេចចិត្តថាត្រូវចូលរួម ក្នុងការសម្ភាស ឬអាចមិនចូលរួមបាន។ ចំពោះឯកសារផ្សេងៗដែលបានជ្រើសរើស និងបានដកស្រង់ អ្នកស្រាវជ្រាវបានរៀបជាឯកសារយោងឱ្យបានត្រឹមត្រូវ ដោយមានបញ្ជាក់ពីចំណងជើង ឆ្នាំបោះពុម្ព ឈ្មោះអ្នកនិពន្ធ ដែលបានដកស្រង់មកផងដែរ។

## លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

### លទ្ធផលស្រាវជ្រាវ

ការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនីលើចំណេះដឹងវិជ្ជាជីវៈ

តារាង៤ *ការយល់ឃើញរបស់សិស្សលើចំណេះដឹងវិជ្ជាជីវៈ (*ចំណេះ*ដឹងអំពីខ្លឹមសារមេរៀន ចំណេះដឹងទូទៅ និងចំណេះដឹងអំពីសិស្ស)*

| បរិយាយ | ទឹកល្អក់ (n=26) | | រំ.សាមគ្គី (n=140) | | រួម (Overall) (n=166) | | P-value |
|---|---|---|---|---|---|---|---|
| | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1. កម្មសិក្សាការី ការិនីមិនមានចំណេះដឹងច្រើនទៅលើមុខវិជ្ជាបង្រៀន | 0.35 | មិនយល់ស្រប | 0.40 | មិនយល់ស្រប | 0.37 | មិនយល់ស្រប | 0.008* |
| 2. ការឆ្លើយសំណួររបស់កម្មសិក្សាការី ការិនីមានភាពអាក់អួល | 0.37 | មិនយល់ស្រប | 0.40 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.030* |
| 3. កម្មសិក្សាការី ការិនីមិនមានចំណេះដឹង ផ្សេងៗក្រៅពីមេរៀនដែលខ្លួនបង្រៀន | 0.37 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.724 |
| 4. កម្មសិក្សាការី ការិនីមិនស្គាល់ពីស្ថានភាពរបស់សិស្ស ។ | 0.65 | យល់ស្រប | 0.69 | យល់ស្រប | 0.67 | យល់ស្រប | 0.476 |

ប្រភព៖ អ្នកនិពន្ធ (កម្រងសំណួរស្ទង់មតិសម្រាប់សិស្ស (2023))

សម្គាល់:

- សន្ទស្សន៍តម្លៃមធ្យម គឺប្រើប្រាស់ការវាស់វែងលើតម្លៃ 5កម្រិត [មិនយល់ស្របខ្លាំង= 0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, យល់ស្របខ្លាំង = 0.81-1.00]; រង្វាយតម្លៃ គឺជាលទ្ធផលដែលបានពីសន្ទស្សន៍តម្លៃមធ្យមដោយប្រើប្រាស់ឃ្លាសម្គាល់
- * Significant at 5%; significant at the 0.05 level; ** significant at the 0.01 level; and *** significant at the 0.001 level.

យោងតាមតារាងទី៤ លទ្ធផលសិក្សាបង្ហាញថា សិស្សភាគច្រើនមានការយល់ឃើញវិជ្ជមានចំពោះចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី ក្នុងការបង្រៀន។ ជាក់ស្តែង សិស្សភាគច្រើនបានឆ្លើយនៅកម្រិត មិនយល់ស្របចំពោះអថេរដែលពាក់ព័ន្ធនឹងមិនមានចំណេះដឹងច្រើនលើមុខវិជ្ជាបង្រៀន ការឆ្លើយប្រយោគមានភាពអាក់អួល និងមិនមានចំណេះដឹងផ្សេងៗក្រៅពីមេរៀនដែលខ្លួនបង្រៀន ។ លទ្ធផលនេះបញ្ជាក់ថា សិស្សយល់ថា កម្មសិក្សាការី ការិនី មានចំណេះមិនមានដឹងលើមុខវិជ្ជាឯកទេសសមស្រប មិនមានចំណេះដឹងវិជ្ជាជីវៈគ្រប់គ្រាន់ និងមិនអាចឆ្លើយសំណួរ ពន្យល់មេរៀនឱ្យបានច្បាស់លាស់ក្នុងអំឡុងពេលបង្រៀន។ ផ្ទុយទៅវិញ អថេរដែលពាក់ព័ន្ធនឹងការមិនទាន់ស្គាល់ស្ថានភាពសិស្សទទួលបានការឆ្លើយនៅកម្រិត យល់ស្របខ្លាំង ដែលបង្ហាញថា សិស្សយល់ថា កម្មសិក្សាការី ការិនី នៅមានបទពិសោធន៍កម្រក្នុងការយល់ដឹងពីបរិបទ និងស្ថានភាពផ្ទាល់ខ្លួនរបស់សិស្ស។ លទ្ធផលស្ថិតិសាស្ត្របន្ថែមបានបង្ហាញថា អថេរមិនមានចំណេះដឹងច្រើនលើមុខវិជ្ជាបង្រៀន មានភាពខុសគ្នាជាអត្ថន័យរវាងសិស្សនៃវិទ្យាល័យទាំងពីរ (P-value = 0.008 < 0.05) ដោយវិទ្យាល័យទឹកល្អក់មានតម្លៃមធ្យម 0.35 ខណៈដែលវិទ្យាល័យជាស៊ីមសាមគ្គីមានតម្លៃមធ្យម 0.40។ ជាមួយគ្នានេះដែរ អថេរដែលពាក់ព័ន្ធនឹងការឆ្លើយសំណួរ មានភាពអាក់អួល ក៏មានភាពខុសគ្នាជាអត្ថន័យស្ថិតិសាស្ត្ររវាងវិទ្យាល័យទាំងពីរ (P-value = 0.030 < 0.05) ដែលបង្ហាញថា ការយល់ឃើញរបស់សិស្សចំពោះសមត្ថភាពឆ្លើយសំណួររបស់កម្មសិក្សាការី ការិនី មានភាពខុសគ្នា ប៉ុន្តែជាទូទៅ សិស្សនៅតែវាយតម្លៃថា កម្មសិក្សាការី ការិនី មានសមត្ថភាពច្បាស់លាស់ក្នុងការឆ្លើយសំណួរ និងបំពេញភារកិច្ចបង្រៀនបានល្អ។ ចំពោះអថេរដែលមាន P-value > 0.05 ដូចជា «កម្មសិក្សាការី ការិនី មិនមានចំណេះដឹងផ្សេងៗក្រៅពីមេរៀនដែលខ្លួនបង្រៀន» (P-value = 0.724) និង «កម្មសិក្សាការី ការិនី មិនស្គាល់ពីស្ថានភាពរបស់សិស្ស» (P-value = 0.476) លទ្ធផលបង្ហាញថា សិស្សនៃវិទ្យាល័យទាំងពីរមានការយល់ឃើញ

ប្រហាក់ប្រហែលគ្នា។ ទោះបីជាមិនមានភាពខុសគ្នាជាអត្ថន័យក៏ដោយ អថេរ «មិនស្គាល់ពីស្ថានភាពរបស់សិស្ស» ទទួលបានសន្ទស្សន៍តម្លៃមធ្យមខ្ពស់ (0.67) នៅកម្រិតយល់ស្រប ដែលបង្ហាញថា ភាពខ្វះខាតសំខាន់ដែលត្រូវបានរកឃើញគឺ កម្មសិក្សាការី ការិនី នៅមិនទាន់យល់ដឹងច្បាស់អំពីបរិបទ តម្រូវការ និងស្ថានភាពផ្ទាល់ខ្លួនរបស់សិស្ស ដោយសារបទពិសោធន៍ និងរយៈពេលកម្មសិក្សានៅមានកម្រិត។ ជាក់ស្តែងយោងតាមការសម្ភាសស៊ីជម្រៅទៅលើសិស្សនៃវិទ្យាល័យទឹកល្អក់នឹងវិទ្យាល័យជាស៊ីមសាមគ្គីបានលើកឡើងថា៖

*“…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនីមានចំណេះដឹងលើមុខវិជ្ជាឯកទេសច្បាស់លាស់ ព្រមទាំងមានចំណេះទូទៅសមស្រប ប៉ុន្តែខ្ញុំយល់គាត់មិនស្គាល់ពីតម្រូវការរបស់សិស្សដោយសារ…។” [សិស្សទី១]*

*“…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនីមានចំណេះដឹងលើមុខវិជ្ជាឯកទេសច្បាស់លាស់ ព្រោះការពន្យល់មេរៀនរបស់គាត់ធ្វើឱ្យខ្ញុំឆាប់យល់ ព្រមទាំងមានចំណេះទូទៅសមស្រប…។”[សិស្សទី២]*

**ទស្សនទានរបស់សិស្សចំពោះកម្មសិក្សាការី ការិនីលើការប្រតិបត្តិវិជ្ជាជីវៈ**

តារាង៥ *ការយល់ឃើញរបស់សិស្សលើការប្រតិបត្តិវិជ្ជាជីវៈ (ការគ្រប់គ្រងបរិស្ថានសិក្សា)*

| បរិយាយ | ទឹកល្អក់ n=26) | | វិ.សាមគ្គី (n=140) | | រួម (Overall) (n=166) | | P-value |
|---|---|---|---|---|---|---|---|
| | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | |
| 1. អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី ក្នុងថ្នាក់មានភាពរញ៉េរញ៉ៃ ) សិស្សឡូឡា ( ។ | 0.40 | មិនយល់ស្រប | 0.43 | ធម្មតា | 0.42 | ធម្មតា | 0.421 |
| 2. ក្នុងថ្នាក់រៀន មិនមានអនាម័យ អំឡុងពេលរៀន ជាមួយកម្មសិក្សាការី ការិនី ។ | 0.43 | ធម្មតា | 0.43 | ធម្មតា | 0.43 | ធម្មតា | 0.910 |
| 3. ក្នុងថ្នាក់រៀនមិនមានវិន័យច្បាស់លាស់និងគ្មានសណ្តាប់ធ្នាប់ អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី ។ | 0.37 | មិនយល់ស្រប | 0.39 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.600 |
| 4. អំឡុងពេលបង្រៀនកម្មសិក្សាការី ការិនីមិនមានការ ចាប់អារម្មណ៍នឹងសកម្មភាពរបស់សិស្សក្នុងថ្នាក់ ។ | 0.35 | មិនយល់ស្រប | 0.39 | មិនយល់ស្រប | 0.37 | មិនយល់ស្រប | 0.171 |
| 5. កម្មសិក្សាការី ការិនីបង្រៀនមេរៀនយូរ មិនមានការចេញលេង។ | 0.49 | ធម្មតា | 0.43 | ធម្មតា | 0.46 | ធម្មតា | 0.205 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 6. អំឡុងពេលបង្រៀន កម្មសិក្សាការី ការិនីនិយាយតិច មិនសូវឮដល់សិស្សគ្រប់គ្នា ។ | 0.48 | ធម្មតា | 0.47 | ធម្មតា | 0.48 | ធម្មតា | 0.750 |
| 7. កម្មសិក្សាការី ការិនីមិនបានយកចិត្តទុកដាក់លើការបង្រៀនសិស្ស ។ | 0.29 | មិនយល់ស្រប | 0.39 | យល់ស្រប | 0.34 | មិនយល់ស្រប | 0.000*** |

ប្រភព៖ អ្នកនិពន្ធ (កម្រងសំណួរស្ទង់មតិសម្រាប់សិស្ស (2023)

សម្គាល់:

- សន្ទស្សន៍តម្លៃមធ្យម គឺប្រើប្រាស់ការវាស់វែងលើតម្លៃ 5កម្រិត] មិនយល់ស្របខ្លាំង =0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, យល់ស្របខ្លាំង = 0.81-1.00]; រង្វាយតម្លៃ គឺជាលទ្ធផលដែលបានពីសន្ទស្សន៍តម្លៃមធ្យមដោយប្រើប្រាស់ឃ្លាសម្គាល់
- * Significant at 5%; significant at the 0.05 level; * * significant at the 0.01 level; and * * * significant at the 0.001 level.

យោងតាមទិន្នន័យដែលបានវិភាគក្នុងតារាងទី៥ លទ្ធផលសិក្សាបង្ហាញថា ក្នុងចំណោមអថេរសរុប មាន ៣ អថេរដែលសិស្សឆ្លើយនៅកម្រិត មិនយល់ស្រប និង ៤ អថេរដែលសិស្សឆ្លើយនៅកម្រិត ធម្មតា។ សិស្សបានឆ្លើយនៅកម្រិត ធម្មតា ចំពោះអថេរ «ថ្នាក់រៀនមានភាពរញ៉េរញ៉ៃ» «ខ្វះអនាម័យក្នុងថ្នាក់រៀន» «បង្រៀនយូរ មិនមានការចេញលេង» និង «និយាយពន្យល់មេរៀនមិនសូវឮ» ដែលបង្ហាញថា សិស្សទាំងនៅវិទ្យាល័យជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់ យល់ថា បរិយាកាសថ្នាក់រៀនអំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី មានលក្ខណៈសមស្រប និងគោរពពេលវេលាសិក្សា។ ផ្ទុយទៅវិញ សិស្សបានឆ្លើយនៅកម្រិត មិនយល់ស្រប ចំពោះអថេរ «ខ្វះវិន័យ និងសណ្តាប់ធ្នាប់ក្នុងថ្នាក់» «មិនយកចិត្តទុកដាក់លើសកម្មភាពសិស្ស» និង «មិនយកចិត្តទុកដាក់លើការបង្រៀនសិស្ស» ដែលបង្ហាញថា សិស្សយល់ថា ថ្នាក់រៀនអំឡុងពេលអនុវត្តកម្មសិក្សាគរុកោសល្យ ត្រូវមានវិន័យ សណ្តាប់ធ្នាប់ និងការយកចិត្តទុកដាក់ពីកម្មសិក្សាការី ការិនី។ លទ្ធផលស្ថិតិសាស្ត្របង្ហាញថា អថេរ «មិនយកចិត្តទុកដាក់លើការបង្រៀនសិស្ស» មានភាពខុសគ្នាជាអត្ថន័យរវាងសិស្សនៃវិទ្យាល័យទាំងពីរ (P-value = 0.000 < 0.05) ដោយវិទ្យាល័យជាស៊ីមសាមគ្គីមានតម្លៃមធ្យម 0.39 ខណៈដែលវិទ្យាល័យទឹកល្អក់មានតម្លៃមធ្យម 0.29 ដែលបង្ហាញពីភាពខុសគ្នានៃការយល់ឃើញរបស់សិស្សចំពោះកម្រិតការយកចិត្តទុកដាក់របស់កម្មសិក្សាការី ការិនី ក្នុងអំឡុងពេលបង្រៀន។ ចំពោះអថេរដទៃទៀតដែលទទួលបានតម្លៃ P-value > 0.05 លទ្ធផលបង្ហាញថា មិនមានភាពខុសគ្នាជាអត្ថន័យ រវាងការយល់ឃើញរបស់សិស្សនៅវិទ្យាល័យទឹកល្អក់ និងវិទ្យាល័យជាស៊ីមសាមគ្គីនោះទេ។ នេះបង្ហាញថា សិស្សនៃវិទ្យាល័យទាំងពីរមានការយល់ឃើញប្រហាក់ប្រហែលគ្នាចំពោះចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី។ ទោះជាមិនមានភាពខុសគ្នាជាអត្ថន័យក៏ដោយ លទ្ធផលបានបង្ហាញពីចំណុចខ្វះខាតមួយចំនួនដែលគួរយកចិត្តទុកដាក់។ ជាពិសេស សិស្សមួយចំនួនបានលើកឡើងថា កម្មសិក្សាការី ការិនី នៅមិនទាន់ស្គាល់ច្បាស់ពីតម្រូវការ សមត្ថភាព និងស្ថានភាពផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ ដែលអាចបណ្តាលមកពីបទពិសោធន៍បង្រៀន និងរយៈពេលកម្មសិក្សានៅមានកម្រិត។ លើសពីនេះ ទោះបីសិស្សបានវាយតម្លៃវិជ្ជមានចំពោះចំណេះដឹងឯកទេស និងចំណេះដឹងទូទៅរបស់កម្មសិក្សាការី ការិនី ក៏ដោយ ប៉ុន្តែលទ្ធផលនេះបង្ហាញថា ភាពខ្វះខាតដែលរកឃើញមិនមែនស្ថិតនៅលើចំណេះដឹងមុខវិជ្ជា ឬសមត្ថភាពពន្យល់មេរៀននោះទេ ប៉ុន្តែស្ថិតនៅលើការយល់ដឹងអំពីសិស្ស និងការសម្របខ្លួនទៅនឹងបរិបទជាក់ស្តែងក្នុងថ្នាក់រៀន ដែលជាជំនាញសំខាន់មួយសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននាពេលអនាគត។ ជាក់ស្តែងតាមរយៈការសម្ភាសទៅលើសិស្សនៃវិទ្យាល័យទាំងពីរបានលើកឡើងថា៖

*"…សម្រាប់ខ្ញុំយល់ថា ការគ្រប់គ្រងបរិស្ថានសិក្សារបស់កម្មសិក្សាការី ការិនីមានលក្ខណៈសមស្រប ប៉ុន្តែខ្ញុំយល់ថាពួកគេមិនសូវយកចិត្តក្នុងការបង្រៀនទេ ដោយសារអំឡុងពេលបង្រៀនគាត់មិនសូវចាប់ពីសិស្ស …។" [សិស្សទី១]*

*"…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនី គ្រប់គ្រងបរិស្ថានសិក្សាបានសមស្របតាមបរិបទ ព្រមទាំងបានយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្ស …។" [សិស្សទី២]*

តារាង៦ *ការយល់ឃើញ របស់សិស្សលើការប្រតិបត្តិវិជ្ជាជីវៈ (វិធីសាស្ត្របង្រៀន)*

| បរិយាយ | ទឹកល្អក់ (n=26) | | វិ.សាមគ្គី (n=140) | | រួម (Overall) (n=166) | | P-value |
|---|---|---|---|---|---|---|---|
| | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | |
| 1. ការរៀបចំមេរៀនបង្រៀនរបស់កម្មសិក្សាការី ការិនីមានលក្ខណៈ ស្មុគស្មាញ ឬពិបាកយល់ ។ | 0.48 | ធម្មតា | 0.44 | ធម្មតា | 0.46 | ធម្មតា | .472 |
| 2. ការពន្យល់មេរៀន របស់កម្មសិក្សាការី ការិនី ធ្វើឱ្យប្អូនៗពិបាកយល់ និង មានអារម្មណ៍ថាស្មុគស្មាញ ។ | 0.37 | មិនយល់ស្រប | 0.39 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.494 |
| 3. អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី មានការបែងចែកក្រុមញឹកញាប់ ហើយមានភាពរញ៉េរញ៉ៃ ។ | 0.49 | ធម្មតា | 0.66 | យល់ស្រប | 0.58 | ធម្មតា | 0.002* |
| 4. ប្អូនយល់ថា កម្មសិក្សាការី ការិនី ប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ហើយប្លែក ៗ ដែលប្អូនមិនធ្លាប់បានជួប ។ | 0.75 | យល់ស្រប | 0.75 | យល់ស្រប | 0.75 | យល់ស្រប | 0.923 |
| 5. ប្អូនៗ ធ្លាប់បានស្គាល់ ឬធ្លាប់រៀនជាមួយពីវិធីសាស្ត្រដែលកម្មសិក្សាការី ការិនីបានបង្រៀនប្អូន ។ | 0.43 | ធម្មតា | 0.56 | ធម្មតា | 0.50 | ធម្មតា | 0.006* |
| 6. ប្អូនយល់ថា អំឡុងពេលបង្រៀនកម្មសិក្សាការី ការិនី បង្រៀនលឿន ឬពន្យល់លឿន ។ | 0.36 | មិនយល់ស្រប | 0.44 | ធម្មតា | 0.40 | មិនយល់ស្រប | 0.050 |
| 7. ប្អូនយល់ថា កម្មសិក្សាការី ការិនី ត្រូវមានជំនាញគរុកោសល្យក្នុងការបង្រៀន គ្រប់គ្រងសិស្ស | 0.72 | យល់ស្រប | 0.75 | យល់ស្រប | 0.73 | យល់ស្រប | 0.508 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រប់គ្រងថ្នាក់រៀន គ្រប់គ្រងបរិយាកាសសិក្សា គ្រប់គ្រងពេលវេលាសិក្សា ។ | | | | | | | |
| 8. តើប្អូនពេញចិត្ត នឹងសកម្មភាពថ្មីៗ ដែលកម្មសិក្សាការី ការិនីបានបង្រៀនដែរឬទេ? | 0.87 | យល់ស្របខ្លាំង | 0.78 | យល់ស្រប | 0.83 | យល់ស្របខ្លាំង | 0.002* |

ប្រភព៖ អ្នកនិពន្ធ (កម្រងសំណួរស្ទង់មតិសម្រាប់សិស្ស (2023))

សម្គាល់:

- សន្ទស្សន៍តម្លៃមធ្យម គឺប្រើប្រាស់ការវាស់វែងលើតម្លៃ 5កម្រិត] មិនយល់ស្របខ្លាំង =0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, យល់ស្របខ្លាំង = 0.81-1.00]; រង្វាយតម្លៃ គឺជាលទ្ធផលដែលបានពីសន្ទស្សន៍តម្លៃមធ្យមដោយប្រើប្រាស់ឃ្លាសម្គាល់
- * Significant at 5%; significant at the 0.05 level; ** significant at the 0.01 level; and *** significant at the 0.001 level.

យោងតាមតារាងខាងលើ លទ្ធផលស្ទង់មតិសិស្សនៅវិទ្យាល័យជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់ បង្ហាញថា ការយល់ឃើញរបស់សិស្សចំពោះការបង្រៀនរបស់កម្មសិក្សាការី ការិនី ត្រូវបានបែងចែកតាមកម្រិតយល់ឃើញផ្សេងៗគ្នា។ ជាក់ស្តែង សិស្សភាគច្រើនឆ្លើយក្នុងកម្រិត ធម្មតា ចំពោះអថេរ ការរៀបចំមេរៀនមានភាពស្មុគស្មាញឬពិបាកយល់ ការបែងចែកក្រុមក្នុងថ្នាក់ញឹកញាប់ហើយមានភាពរញ៉េរញ៉ៃ និងធ្លាប់បានស្គាល់ ឬធ្លាប់រៀនជាមួយពីវិធីសាស្ត្រ ដែលបញ្ជាក់ថាសកម្មភាពបង្រៀនមានលក្ខណៈសមស្របទៅតាមបរិបទថ្នាក់រៀន។ ចំណែកឯអថេរ មិនយល់ស្រប មានដូចជា ពិបាកយល់ និង មានអារម្មណ៍ថាស្មុគស្មាញ និងបង្រៀនលឿន ឬពន្យល់លឿន សិស្សបង្ហាញមតិ ដែលបញ្ជាក់ថាការពន្យល់មេរៀនរបស់កម្មសិក្សាការី ការិនី មិនមែនជាបញ្ហាសម្រាប់សិស្សភាគច្រើននោះទេ។ ផ្ទុយមកវិញ សិស្សបានបង្ហាញការយល់ស្របចំពោះអថេរដែលបានលើកឡើងនោះមាន ប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ហើយប្លែក ៗ ដែលប្អូនមិនធ្លាប់បានជួប និងត្រូវមានជំនាញគរុកោសល្យក្នុងការបង្រៀន គ្រប់គ្រងសិស្ស គ្រប់គ្រងថ្នាក់រៀន គ្រប់គ្រងបរិយាកាសសិក្សា គ្រប់គ្រងពេលវេលាសិក្សា ដែលបានបង្ហាញពីការយល់ឃើញជារួមពីជំនាញគរុកោសល្យរបស់ពួកគាត់ ដែលឆ្លុះបញ្ចាំងពីការទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី។ លើសពីនេះ ទើបមានតែអថេរមួយប៉ុណ្ណោះដែលសិស្សបង្ហាញការយល់ស្របខ្លាំង បញ្ជាក់ពីមតិវិជ្ជមានខ្ពស់ចំពោះការបង្រៀនសកម្មភាពថ្មីៗ។ ជាមួយគ្នានេះផងដែរ លទ្ធផលវិភាគបានបង្ហាញអថេរមួយចំនួនដែលមានភាពខុសគ្នារវាងវិទ្យាល័យជាស៊ីមសាមគ្គី និងវិទ្យាល័យទឹកល្អក់។ ចំពោះអថេរ ល្បឿនបង្រៀន ឬការពន្យល់មេរៀន សិស្សនៅវិទ្យាល័យទឹកល្អក់មានទំនោរបង្ហាញមតិ មិនយល់ស្រប ច្បាស់ថាកម្មសិក្សាការី ការិនី បង្រៀនលឿនពេក ខណៈសិស្សនៅវិទ្យាល័យជាស៊ីមសាមគ្គីឆ្លើយក្នុងកម្រិត ធម្មតា ដែលអាចពាក់ព័ន្ធនឹងចំនួនសិស្សក្នុងថ្នាក់រៀន។ បន្ថែមពីនេះ អថេរ ការបែងចែកក្រុម និងភាពរញ៉េរញ៉ៃក្នុងថ្នាក់ សិស្សនៅវិទ្យាល័យជាស៊ីមសាមគ្គីមានទំនោរ យល់ស្រប ថាការបែងចែកក្រុមអាចបង្កភាពរញ៉េរញ៉ៃ ខណៈសិស្សនៅវិទ្យាល័យទឹកល្អក់ឆ្លើយក្នុងកម្រិត ធម្មតា ហើយអថេរនេះមានភាពខុសគ្នាជាស្ថិតិសំខាន់ (P-value = 0.002 < 0.05)។ ជារួម ភាពខុសគ្នានៃការយល់ឃើញរវាងសាលាទាំងពីរ ពាក់ព័ន្ធជាចម្បងនឹងបរិបទថ្នាក់រៀន ជាពិសេសចំនួនសិស្ស ដែលមានឥទ្ធិពលដល់ប្រសិទ្ធភាពនៃការបង្រៀន និងការគ្រប់គ្រងសកម្មភាពសិក្សា។ ដោយឡែកចំពោះប្រយោគ "ប្អូនៗ ធ្លាប់បានស្គាល់ ឬធ្លាប់រៀនជាមួយពីវិធីសាស្ត្រដែលកម្មសិក្សាការី ការិនីបានបង្រៀនប្អូន" បង្ហាញថាសិស្សមានការយល់ឃើញខុសគ្នាជាអត្ថន័យ ដោយសារ (P-value = 0.006 < 0.05) ដែលបង្ហាញថាវិធីសាស្ត្រដែលកម្មសិក្សាការី ការិនីបានប្រើប្រាស់ក្នុងការបង្រៀន គឺពួកគេ បានធ្លាប់រៀននិងស្គាល់និងធ្លាប់បានរៀន។ ចំពោះសំណួរ "តើប្អូនពេញចិត្ត នឹងសកម្មភាពថ្មីៗ ដែលកម្មសិក្សាការី ការិនីបានបង្រៀនដែរឬទេ" បង្ហាញថាសិស្សមានការយល់ឃើញ

ខុសគ្នាជាអត្ថន័យ ដែលក្នុងនោះសិស្សនៅវិទ្យាល័យទឹកល្អក់ ឆ្លើយថា យល់ស្របខ្លាំង និងសិស្សនៅវិទ្យាល័យជាស៊ីមសាមគ្គី ឆ្លើយថា យល់ស្រប ដែលបញ្ជាថាសិស្សទាំងពីរវិទ្យាល័យពេញចិត្តនឹង សកម្មភាពថ្មីៗប្លែក ដែលកម្មសិក្សាការី ការិនីបានប្រើប្រាស់ក្នុងការបង្រៀនដល់ពួកគេ (P-value =0.002<0.05)។ ជាក់ស្តែងតាមរយៈការ សម្ភាសស៊ីជម្រៅទៅលើសិស្សនៃវិទ្យាល័យទាំងពីរបង្ហាញថា៖

*"...សម្រាប់ខ្ញុំយល់ថា វិធីសាស្ត្របង្រៀនរបស់កម្មសិក្សាការី ការិនីមានលក្ខណៈថ្មីប្លែកសម្រាប់ខ្ញុំ ហើយខ្ញុំពេញចិត្តនឹងសកម្មភាពថ្មីៗដែលកម្មសិក្សាការី ការិនីបានផ្តល់ជូន...។" [សិស្សទី១]*

*"…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនី មានជំនាញគរុកោសល្យក្នុងការបង្រៀន គ្រប់គ្រងពេលវេលាសិក្សា ប្រើប្រាស់នូវវិធីសាស្ត្រថ្មីៗដែលខ្ញុំមិនធ្លាប់បានស្គាល់ពីមុន...។" [សិស្សទី២]*

**ការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនីលើការសិក្សាវិជ្ជាជីវៈ**

តារាង៧ *ការយល់ឃើញរបស់សិស្សលើការសិក្សាវិជ្ជាជីវៈ(បំណិនក្នុងការទំនាក់ទំនង និងបំណិនក្នុងការបង្រៀន)*

| បរិយាយ | ទឹកល្អក់ (n=26) | | វិ.សាមគ្គី (n=140) | | រួម (Overall) (n=166) | | P-value |
|---|---|---|---|---|---|---|---|
| | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | |
| 1. ប្អូនយល់ថា កម្មសិក្សាការី ការិនីមិនមានទំនាក់ទំនងជាមួយសិស្សនៅក្នុងថ្នាក់ ហើយនឹងកម្មសិក្សាការី ការិនីដូចគ្នា។ | 0.35 | មិនយល់ស្រប | 0.36 | មិនយល់ស្រប | 0.36 | មិនយល់ស្រប | 0.773 |
| 2. ប្អូនយល់ថា កម្មសិក្សាការី ការិនីមិនមានបទពិសោធក្នុងការបង្រៀន។ | 0.72 | យល់ស្រប | 0.63 | យល់ស្រប | 0.67 | យល់ស្រប | 0.160 |

ប្រភព៖ អ្នកនិពន្ធ (កម្រងសំណួរស្ទង់មតិសម្រាប់សិស្ស (2023))

សម្គាល់:

- សន្ទស្សន៍តម្លៃមធ្យម គឺប្រើប្រាស់ការវាស់វែងលើតម្លៃ 5កម្រិត] មិនយល់ស្របខ្លាំង =0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, យល់ស្របខ្លាំង = 0.81-1.00]; វង្វាយតម្លៃ គឺជាលទ្ធផលដែលបានពីសន្ទស្សន៍តម្លៃមធ្យមដោយប្រើប្រាស់ឃ្លាសម្គាល់
- * Significant at 5%; significant at the 0.05 level; ** significant at the 0.01 level; and *** significant at the 0.001 level.

យោងតាមតារាងខាងលើបង្ហាញថា តាមរយៈប្រយោគ "ប្អូនយល់ថា កម្មសិក្សាការី ការិនីមិនមានបទពិសោធក្នុងការបង្រៀន" បង្ហាញថា យល់ស្រប ដោយពួកគេយល់ថា កម្មសិក្សាការី ការិនីគឺមិនមានបទពិសោធន៍ក្នុងការបង្រៀនកន្លងមក។ ផ្ទុយទៅវិញ ចំពោះប្រយោគ "ប្អូនយល់ថា កម្មសិក្សាការី ការិនីមិនមានទំនាក់ទំនងជាមួយសិស្សនៅក្នុងថ្នាក់ ហើយនឹងកម្មសិក្សាការី ការិនីដូចគ្នា" សិស្សឆ្លើយថា មិនយល់ស្រប ដែលបង្ហាញថា កម្មសិក្សាការី ការិនីគឺតែងមានទំនាក់ទំនងជាមួយសិស្ស និងកម្មសិក្សាការី ការិនីក៏ដូចជាលោកគ្រូលោកគ្រូ អ្នកគ្រូដែលបង្រៀននៅសាលា ដៃគូរផងដែរ។ តាមរយៈលទ្ធផលខាងលើនេះបង្ហាញថា ការយល់ឃើញរបស់សិស្សទៅលើប្រយោគទាំងពីរ មិនមានភាពខុសគ្នានោះទេ ដោយ (P-value > 0.05)។

*“…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនីមិនមានបទពិសោធក្នុងការបង្រៀន ប៉ុន្តែមានទំនាក់ទំនងល្អ ជាមួយសិស្ស លោកគ្រូលោកគ្រូ អ្នកគ្រូ និងជាមួយកម្មសិក្សាការី ការិនី …។” [សិស្សទី១]*

*“…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនី មានទំនាក់ទំនងល្អជាមួយលោកគ្រូលោកគ្រូ អ្នកគ្រូ និងកម្មសិក្សាការី ការិនី ប៉ុន្តែខ្ញុំយល់ថាកម្មសិក្សាការី និងការិនី មិនមានបទពិសោធច្រើនក្នុងការបង្រៀន …។” [សិស្សទី២]*

**ការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនីលើសីលធម៌វិជ្ជាជីវៈ**

តារាង៨ *ការយល់ឃើញរបស់សិស្សលើសីលធម៌វិជ្ជាជីវៈ (ការយកចិត្តទុកដាក់ អាកប្បកិរិយាវិជ្ជមាន ភាពយុត្តិធម៌ និងតម្លាភាព និងការគោរពពេលវេលា )*

| បរិយាយ | ទឹកល្អក់ (n=26) | | វិ.សាមគ្គី (n=140) | | រួម ( Overall) (n=166) | | P-value |
|---|---|---|---|---|---|---|---|
| | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | សន្ទស្សន៍តម្លៃមធ្យម | វង្វាយតម្លៃ | |
| 1. កម្មសិក្សាការី ការិនី ប្រើកាយវិការមិនសមរម្យ )វាយ មួល ( និងប្រើប្រាស់ពាក្យសម្ដីមិនសមរម្យក្នុងពេលបង្រៀន។ | 0.32 | មិនយល់ស្រប | 0.37 | មិនយល់ស្រប | 0.35 | មិនយល់ស្រប | 0.227 |
| 2. ប្អូនយល់ថា កម្មសិក្សាការី ការិនីគ្មានការលើកទឹកចិត្ត ដល់សិស្ស។ | 0.35 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.37 | មិនយល់ស្រប | 0.549 |
| 3. អំឡុងពេលបង្រៀនកម្មសិក្សាការី ការិនី ស្លៀកពាក់មិនបានសមរម្យ។ | 0.33 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.36 | មិនយល់ស្រប | 0.146 |
| 4. កម្មសិក្សាការី ការិនីមិនគោរពពេលវេលា មកយឺតជាញឹកញាប់អំឡុងពេលបង្រៀន។ | 0.31 | មិនយល់ស្រប | 0.40 | មិនយល់ស្រប | 0.35 | មិនយល់ស្រប | 0.009* |
| 5. មិនមានភាពយុត្តិធម៌ អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី។ | 0.32 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.35 | មិនយល់ស្រប | 0.102 |
| 6. អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី មិនមានសមភាព ហៅសិស្សប្រុស ) ឆ្លើយញឹកញាប់ជាងសិស្សស្រីឬសិស្សស្រីញឹកញាប់ជាងសិស្សប្រុស ។ ( | 0.31 | មិនយល់ស្រប | 0.41 | ធម្មតា | 0.36 | មិនយល់ស្រប | 0.006* |
| 7. អំឡុងពេលបង្រៀនកម្មសិក្សាការី ការិនី មិនមានការគោរពឱ្យ | 0.32 | មិនយល់ស្រប | 0.40 | មិនយល់ស្រប | 0.36 | មិនយល់ស្រប | 0.032* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| តម្លៃដល់សិស្ស និងកម្មសិក្សាការី ការិនីផ្សេងៗទៀត។ | | | | | | | |
| 8. អំឡុងពេលរៀន កម្មសិក្សាការី ការិនីដោះស្រាយបញ្ហាសិស្សដោយប្រើវិន័យអវិជ្ជមាន។(ហិង្សា) | 0.35 | មិនយល់ស្រប | 0.38 | មិនយល់ស្រប | 0.36 | មិនយល់ស្រប | 0.487 |
| 9. ប្អូនយល់ថា កម្មសិក្សាការី ការិនីជាបុគ្គលដែលមានចិត្តអំណត់ មិនឆេវឆាវ ។ | 0.79 | យល់ស្រប | 0.75 | យល់ស្រប | 0.77 | យល់ស្រប | 0.200 |
| 10. ប្អូនពេញចិត្តនឹងការបង្រៀនរបស់កម្មសិក្សាការី ការិនី។ | 0.84 | យល់ស្របខ្លាំង | 0.82 | យល់ស្របខ្លាំង | 0.83 | យល់ស្របខ្លាំង | 0.756 |

ប្រភពៈអ្នកនិពន្ធ (កម្រងសំណួរស្ទង់មតិសម្រាប់សិស្ស (2023))

សម្គាល់:

- សន្ទស្សន៍តម្លៃមធ្យម គឺប្រើប្រាស់ការវាស់វែងលើតម្លៃ 5កម្រិត] មិនយល់ស្របខ្លាំង =0.00-0.20, មិនយល់ស្រប = 0.21-0.40, ធម្មតា = 0.41-0.60, យល់ស្រប = 0.61-0.80, យល់ស្របខ្លាំង = 0.81-1.00]; វង្វាយតម្លៃ គឺជាលទ្ធផលដែលបានពីសន្ទស្សន៍តម្លៃមធ្យមដោយប្រើប្រាស់ឃ្លាសម្គាល់
- *Significant at 5%; Significant at the 0.05 level; **Significant at the 0.01 level; and *** significant at the 0.001 level.

យោងតាមតារាងខាងលើ ទិន្នន័យបង្ហាញថា ក្នុងចំណោមប្រយោគសរុប មាន ៨ ប្រយោគដែលសិស្សឆ្លើយថា មិនយល់ស្រប តែ ១ ប្រយោគសិស្សឆ្លើយថា យល់ស្រប និង ១ ប្រយោគទៀតសិស្សឆ្លើយថា យល់ស្របខ្លាំង។ ជាក់ស្តែងសិស្សបានឆ្លើយថា មិនយល់ស្រប ចំពោះប្រយោគដូចជា «កម្មសិក្សាការី ការិនី ប្រើកាយវិការមិនសមរម្យ (វាយ មួល) និងប្រើប្រាស់ពាក្យសម្តីមិនសមរម្យក្នុងពេលបង្រៀន» «ប្អូនយល់ថា កម្មសិក្សាការី ការិនីគ្មានការលើកទឹកចិត្តដល់សិស្ស» «អំឡុងពេលបង្រៀន កម្មសិក្សាការី ការិនី ស្លៀកពាក់មិនបានសមរម្យ» «មិនមានភាពយុត្តិធម៌ អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី» និង «អំឡុងពេលរៀន កម្មសិក្សាការី ការិនីដោះស្រាយបញ្ហាសិស្សដោយប្រើវិន័យអវិជ្ជមាន (ហិង្សា)»។ លទ្ធផលទាំងនេះបញ្ជាក់ថា អំឡុងពេលបង្រៀន កម្មសិក្សាការី ការិនី បានប្រើប្រាស់ពាក្យសម្តី កាយវិការ និងការស្លៀកពាក់បានសមរម្យ គោរពពេលវេលា មានសមភាព និងសមធម៌ក្នុងថ្នាក់រៀន ព្រមទាំងមានការលើកទឹកចិត្ត និងបង្កើតទំនាក់ទំនងល្អជាមួយសិស្សនឹងជាគម្រូល្អដល់សិស្សផងដែរ។ ដោយឡែក ចំពោះប្រយោគ «ប្អូនយល់ថា កម្មសិក្សាការី ការិនី ជាបុគ្គលដែលមានចិត្តអំណត់ មិនឆេវឆាវ» សិស្សបានឆ្លើយថា យល់ស្រប ខណៈដែលប្រយោគ «ប្អូនពេញចិត្តនឹងការបង្រៀនរបស់កម្មសិក្សាការី ការិនី» សិស្សបានឆ្លើយថា យល់ស្របខ្លាំង ដែលបង្ហាញពីការពេញចិត្តជាទូទៅចំពោះការបង្រៀន។ ចំពោះប្រយោគ «កម្មសិក្សាការី ការិនី មិនគោរពពេលវេលា មកយឺតជាញឹកញាប់អំឡុងពេលបង្រៀន» លទ្ធផលបង្ហាញថា ការយល់ឃើញរបស់សិស្សនៅវិទ្យាល័យទាំងពីរមានភាពខុសគ្នាជាអត្ថន័យស្ថិតិសាស្ត្រ (P-value = 0.009 < 0.05) ដែលបញ្ជាក់ថា កម្មសិក្សាការី ការិនី បានគោរពពេលវេលា និងវិន័យរបស់សាលាបានត្រឹមត្រូវ។ ជាមួយគ្នានេះដែរ ចំពោះប្រយោគ «អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី មិនមានសមភាព (ហៅសិស្សប្រុសឆ្លើយញឹកញាប់ជាងសិស្សស្រី ឬផ្ទុយមកវិញ)» លទ្ធផលបង្ហាញថា ការយល់ឃើញរបស់សិស្សមានភាពខុសគ្នាជាអត្ថន័យស្ថិតិសាស្ត្រ (P-value = 0.006 < 0.05) ដោយសិស្សនៅវិទ្យាល័យទឹកល្អក់ និងវិទ្យាល័យជាស៊ីមសាមគ្គី សុទ្ធតែយល់ឃើញថា ថ្នាក់រៀនមានសមភាព និងមានការចូលរួមទាំងសិស្សស្រី និងសិស្សប្រុស។ បន្ថែមពីនេះ ចំពោះប្រយោគ «អំឡុងពេលបង្រៀន កម្មសិក្សាការី ការិនី មិនមានការ

គោរពឱ្យតម្លៃដល់សិស្ស និងកម្មសិក្សាការីផ្សេងៗទៀត» លទ្ធផលបង្ហាញថា ការយល់ឃើញរបស់សិស្សមានភាពខុសគ្នាជាអត្ថន័យស្ថិតិសាស្ត្រ (P-value = 0.032 < 0.05) ដោយសិស្សនៅវិទ្យាល័យទាំងពីរ យល់ថា កម្មសិក្សាការី ការិនី មានការគោរព និងឱ្យតម្លៃគ្នាទៅវិញទៅមករវាងគ្រូ និងសិស្ស ក្នុងបរិបទថ្នាក់រៀន។ ក្នុងនោះចំពោះប្រយោគ « ប្អូនពេញចិត្តនឹងការបង្រៀនរបស់កម្មសិក្សាការី ការិនី» ទទួលបាន Mean = 0.83 និង 0.84 ដែលជាតម្លៃវិជ្ជមាន បង្ហាញថាលទ្ធផលនេះឆ្លុះបញ្ចាំងពីការទទួលស្គាល់ជារួមរបស់សិស្សចំពោះគុណភាពនៃការបង្រៀនរបស់កម្មសិក្សាគរុកោសល្យ។ ជាក់ស្តែងតាមរយៈការសម្ភាសស៊ីជម្រៅទៅលើសិស្សនៃវិទ្យាល័យទាំងពីរបង្ហាញថា៖

*“…សម្រាប់ខ្ញុំយល់ថា កម្មសិក្សាការី ការិនីបានយកចិត្តទុកដាក់ និងមានអាកប្បកិរិយា សមរម្យ គោរពពេលវេលា ព្រមទាំងមានភាពយុត្តិធម៌ និងតម្លាភាព …។” [សិស្សទី១]*

*“…ខ្ញុំយល់ថា អំឡុងពេលរៀនជាមួយកម្មសិក្សាការី ការិនី ខ្ញុំមានអារម្មណ៍ថាសប្បាយ រៀនឆាប់យល់ ដោយកម្មសិក្សាការី ការិនី បានយកចិត្តទុកដាក់ និងពន្យល់មេរៀនយ៉ាងក្បោះក្បាយ ដែល ធ្វើឱ្យលទ្ធផល សិក្សារបស់ខ្ញុំ ទទួលបានលទ្ធផលល្អ …។” [សិស្សទី២]*

## ការពិភាក្សា

ជារួមការស្រាវជ្រាវបង្ហាញថា ការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនីគឺវិជ្ជមានចំពោះចំណេះដឹងវិជ្ជាជីវៈ (ចំណេះដឹងអំពីខ្លឹមសារមេរៀន ចំណេះដឹងទូទៅ និងចំណេះដឹងអំពីសិស្ស) ការប្រតិបត្តិវិជ្ជាជីវៈ (ការគ្រប់គ្រងបរិស្ថានសិក្សា និងវិធីសាស្ត្របង្រៀន) ការសិក្សាវិជ្ជាជីវៈ(បំណិនក្នុងការទំនាក់ទំនង និងបំណិនក្នុងការបង្រៀន) និងសីលធម៌វិជ្ជាជីវៈ(ការយកចិត្តទុកដាក់ អាកប្បកិរិយាវិជ្ជមាន ភាពយុត្តិធម៌ និងតម្លាភាព និងការគោរពពេលវេលា )។ លទ្ធផលនៃការស្រាវជ្រាវនេះស្រដៀងជាមួយ Rodriguez et al. (2019) និង Bakx et al. (2015) បានបង្ហាញថា កម្មសិក្សាការី ការិនីមានចំណេះដឹងលើខ្លឹមសារមេរៀន អាចពន្យល់មេរៀន និងឆ្លើយសំណួរសិស្សបានសមស្រប ព្រមទាំងប្រើវិធីសាស្ត្របង្រៀនផ្សេងៗបានមានប្រសិទ្ធភាព។ ដូចគ្នានេះ លទ្ធផលសិក្សាក៏ប្រហែលជាមួយ Turman & Schrodt (2006) ដែលបានបញ្ជាក់ថា ទម្រង់បង្រៀន និងការប្រើប្រាស់អំណាចក្នុងថ្នាក់រៀនមានលក្ខណៈសមស្រប ខណៈ Schambach & Dirks (2002) បង្ហាញថា កម្មសិក្សាការី ការិនីមានទំនាក់ទំនងល្អជាមួយសិស្ស និងប្រើការលើកទឹកចិត្តជាជាងការប្រើអំណាចហិង្សា ដែលឆ្លុះបញ្ចាំងពីសីលធម៌វិជ្ជាជីវៈវិជ្ជមាន។

ទោះយ៉ាងណា Adebakin (2015) បានលើកឡើងថា កម្មសិក្សាការី ការិនីនៅមានបទពិសោធន៍បង្រៀនតិច និងមិនទាន់យល់ដឹងបានពេញលេញអំពីស្ថានភាព និងតម្រូវការរបស់សិស្ស ព្រមទាំងជំនាញមួយចំនួនដូចជា ការរៀបចំមេរៀន និងការគ្រប់គ្រងថ្នាក់។ ដោយផ្អែកតាមលទ្ធផលស្រាវជ្រាវក្នុងតារាងខាងលើ ក៏មានភាពប្រហាក់ប្រហែលគ្នាជាមួយ Adebakin (2015) ដោយសិស្សភាគច្រើនវាយតម្លៃវិជ្ជមានចំពោះចំណេះដឹង និងសមត្ថភាពបង្រៀនរបស់កម្មសិក្សាការី ការិនី ប៉ុន្តែនៅមានការលើកឡើងអំពីការខ្វះបទពិសោធន៍ និងការយល់ដឹងអំពីសិស្ស។

លើសពីនេះលទ្ធផលសិក្សារកឃើញថា បរិយាកាសសិក្សាដែលបង្កើតដោយកម្មសិក្សាការី ការិនីមានទំនាក់ទំនងវិជ្ជមានខ្លាំងជាមួយសមិទ្ធផលសិក្សារបស់សិស្ស ដែលលទ្ធផលស្រាវជ្រាវនេះស្របនឹង Akram (2019) ដែលបង្ហាញថាការគ្រប់គ្រងថ្នាក់ និងបរិយាកាសសិក្សាបានល្អអាចជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សបាន។

## សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញការយល់ឃើញរបស់សិស្សមកលើកម្មសិក្សាការី ការិនីចំពោះ ចំណេះដឹងវិជ្ជាជីវៈថា កម្មសិក្សាការី ការិនី មានចំណេះដឹងឯកទេសបានច្បាស់លាស់នឹងមានចំណេះដឹងក្រៅពីមេរៀនថែមទៀតផង។ ជាមួយគ្នានោះ ការយល់ឃើញរបស់សិស្សទៅលើ ការប្រតិបត្តិវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី បង្ហាញថា ការគ្រប់គ្រងថ្នាក់រៀន មាន

អនាម័យ និងមានវិន័យច្បាស់លាស់។ ក្នុងនោះការរៀបចំមេរៀនសម្រាប់បង្រៀន និង ការពន្យល់មេរៀន របស់កម្មសិក្សាការី ការិនីមិនមានលក្ខណៈ ស្មុគស្មាញ ឬពិបាកយល់នោះទេ ហើយការបង្រៀន ឬពន្យល់ ក៏មិនលឿននោះដែរ ប៉ុន្តែពួកគេយល់ថា កម្មសិក្សាការី ការិនី ប្រើប្រាស់វិធីសាស្ត្រ ថ្មីៗ ក្នុងការបង្រៀនដល់ពួកគេ ចំពោះការបែងចែកក្រុមពិភាក្សា បង្ហាញថាមិនសូវជាមានប្រសិទ្ធភាពនោះទេដោយសារទំហំថ្នាក់រៀនមិនសមស្រប។ ផ្ទុយទៅវិញចំពោះការយល់ឃើញរបស់សិស្សទៅលើការសិក្សាវិជ្ជាជីវៈ សិស្សយល់ឃើញថា កម្មសិក្សាការី ការិនីគឺមិនមានបទពិសោធន៍ក្នុងការបង្រៀន មានទំនាក់ទំនងល្អជាមួយសិស្ស និងកម្មសិក្សាការី ការិនីក៏ដូចជាលោកគ្រូលោកគ្រូ អ្នកគ្រូដែលបង្រៀននៅសាលារៀន ដែគួរផងដែរ។ បន្ថែមពីនេះ ការយល់ឃើញរបស់សិស្សានុសិស្សទៅលើ សីលធម៌វិជ្ជាជីវៈ វិញពួកគេយល់ថា កម្មសិក្សាការី ការិនី ជាបុគ្គល អត់ធ្មត់ ប្រើប្រាស់ពាក្យសម្ដី កាយវិការ និងការស្លៀកពាក់បានសមរម្យ គោរពពេលវេលា និងវិន័យរបស់សាលារៀនបានត្រឹមត្រូវ មានសមភាព និងសមធម៌ ហើយមានការលើកទឹកចិត្ត និងមានទំនាក់ទំនងល្អ និងការគោរព ឱ្យតម្លៃ គ្នាទៅវិញទៅមករវាងគ្រូនិងសិស្ស និងគ្រូដូចគ្នា។

សរុបសេចក្ដីមក ការសិក្សាស្រាវជ្រាវនេះ បានរកឃើញថា កម្មសិក្សាការី ការិនីមានចំណុចវិជ្ជមានមួយចំនួនដូចជាមានចំណេះដឹងឯកទេសសមស្រប មានអាកប្បកិរិយាសមរម្យជាមួយសិស្ស ជាបុគ្គលមានស្មារតីអត់ធ្មត់ អនុវត្តន៍វិធីសាស្ត្របង្រៀនថ្មីៗ ល្អៗក្នុងការបង្រៀន និងមានវិធីសាស្ត្រក្នុងការគ្រប់គ្រងថ្នាក់រៀនល្អ។ ទន្ទឹមនឹងការរកឃើញចំណុចល្អ ការសិក្សាស្រាវជ្រាវនេះ ក៏បានរកឃើញអំពី ចំណុចខ្វះខាតរបស់កម្មសិក្សាការី ការិនីផងដែរគឺមានបទពិសោធន៍តិចក្នុងការបង្រៀន ការប្រើប្រាស់វិធីសាស្ត្រថ្មីៗដែលគេមិនធ្លាប់ជួបឬបានរៀនពីមុនមក និងមិនទាន់ស្គាល់ពីស្ថានភាពរបស់សិស្សដែលជាបញ្ហាមួយក្នុងការអនុវត្តកម្មសិក្សា ដោយសាររយៈពេលនៃការចុះកម្មសិក្សាមានរយៈពេលតិច។ ជាក់ស្ដែងដូចដែលយើងបានដឹងហើយថា វិធីសាស្ត្រគឺសំខាន់នឹងចាំបាច់បំផុត ក្នុងការបង្រៀនដើម្បីធ្វើឱ្យសិស្សទទួលបានលទ្ធផលខ្ពស់ក្នុងការសិក្សា ក៏ប៉ុន្តែក្នុងនោះក៏ទាមទារឱ្យគ្រូត្រូវតែ ស្គាល់ពីស្ថានភាពរបស់សិស្សដោយសង្កេតពីតម្រូវការរបស់សិស្ស។ ការស្គាល់ពីស្ថានភាពរបស់សិស្សគឺសំខាន់ណាស់ ដែលអាចឱ្យយើងងាយស្រួលក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនដល់ពួកគេប្រកបដោយប្រសិទ្ធភាព។

**អនុសាសន៍**

លទ្ធផលសិក្សានេះអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ក្នុងការពង្រឹងការបណ្ដុះបណ្ដាលជំនាញគ្រប់គ្រងថ្នាក់រៀន ការសិក្សាពីបរិបទសិស្ស និងការអភិវឌ្ឍបទពិសោធន៍វិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនីមុនពេលចុះអនុវត្តកម្មសិក្សាគរុកោសល្យ។ ការស្រាវជ្រាវនេះបានផ្ដល់នូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

**អនុសាសន៍ចំពោះគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ៖** តាមរយៈលទ្ធផលនៃការសិក្សានេះ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូមានតួនាទីសំខាន់ក្នុងការកែលម្អសមត្ថភាពបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន។ ជាពិសេស គួរពង្រឹងចំណេះដឹងវិជ្ជាជីវៈ និងបទពិសោធន៍បង្រៀន តាមរយៈការរៀបចំកម្មវិធីកម្មសិក្សា ដើម្បីលើកកម្ពស់ការប្រើវិធីសាស្ត្រថ្មីៗ និងច្នៃប្រឌិតក្នុងការបង្រៀន។

**អនុសាសន៍ចំពោះកម្មសិក្សាការី ការិនី៖** លទ្ធផលនៃការស្រាវជ្រាវនេះផ្ដល់ឱ្យកម្មសិក្សាការី និងការិនី ជាចំណេះដឹងសំខាន់សម្រាប់កែលម្អការបង្រៀន។ វាផ្ដល់ចំណុចអនុវត្តន៍ច្បាស់លាស់ ដូចជា ពង្រឹងបទពិសោធន៍ និងសមត្ថភាពក្នុងការបង្រៀន និងគ្រប់គ្រងថ្នាក់រៀននិងស្គាល់ស្ថានភាពសិស្សក្នុងថ្នាក់ប្រើវិធីសាស្ត្របង្រៀនថ្មីៗ និងសមស្របនិងពង្រឹងទំនាក់ទំនងវិជ្ជា

ជីវៈជាមួយសិស្ស។ ការអនុវត្តចំណុចទាំងនេះអាចជួយឱ្យការបង្រៀនមានប្រសិទ្ធភាពខ្ពស់ លើកទឹកចិត្តសិស្ស និងធ្វើឱ្យពួកគេទទួលបានចំណេះដឹង និងជំនាញយ៉ាងច្បាស់លាស់។

**អនុសាសន៍ចំពោះអ្នកស្រាវជ្រាវបន្ត៖** ការសិក្សាស្រាវជ្រាវលើ គឺជាការស្រាវជ្រាវតូចមួយ ដែលផ្តោតលើការយល់ឃើញរបស់សិស្សចំពោះកម្មសិក្សាការី ការិនី និងមិនអាចធ្វើសេចក្តីសន្និដ្ឋានទូទៅបាន។ អ្នកស្រាវជ្រាវបន្ទាប់ គួរបន្ថែមចំនួនសំណាកគំរូ ដោយមានគ្រូណែនាំ គ្រូដឹកនាំ ឬគណៈគ្រប់គ្រងសាលា ដើម្បីចូលរួមវាយតម្លៃ និងសង្កេតថ្នាក់រៀនជាក់លាក់។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះ ទទួលបានការគាំទ្រ និងការអប់រំបណ្តុះបណ្តាលពីគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ គ្រូឧទ្ទេស គ្រូណែនាំ សាលាសហការ និងគ្រូឧទ្ទេសដឹកនាំ ជាពិសេសក្រសួងអប់រំ យុវជន និង កីឡា ដែលបានផ្តល់ឱកាសឱ្យទទួលបានការសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់និពន្ធនាយក និងអ្នកត្រួតពិនិត្យជំនាញអនាមិក សម្រាប់មតិយោបល់កែលម្អលើអត្ថបទស្រាវជ្រាវនេះ។ ខ្លឹមសារអត្ថបទស្រាវជ្រាវនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីការយល់ឃើញ ឬនិន្នាការនយោបាយរបស់ក្រុមណាមួយឡើយ។

## ឯកសារយោង (References)


Adebakin, A. B. (2015). Does internship experience beget academic relevance and employment prospects? An assessment of graduate interns from a Nigerian university. *Bulgarian Journal of Science and Education Policy, 9*(2), 302–316. https://bjsep.org/getfile.php?id=199

Afornyo, J. E. E. (2018). *Teachers' and students' perceptions on the teaching of integrated science in Abura Asebu Kwamankese District* [Dissertation, University of Cape Coast]. University of Cape Coast Institutional Repository. https://ir.ucc.edu.gh/xmlui/handle/123456789/1058

Akram, M. (2019). Relationship between students' perceptions of teacher effectiveness and student achievement at the secondary school level. *Bulletin of Education and Research, 41*(2), 93–108.

Attride-Stirling, J. (2001). Thematic networks: An analytic tool for qualitative research. *Qualitative Research, 1*(3), 385–405. https://doi.org/10.1177/146879410100100307

Bakx, A., Koopman, M., de Kruijf, J., & den Brok, P. (2015). Primary school pupils' views of characteristics of good primary school teachers: An exploratory, open approach for investigating pupils' perceptions. *Teachers and Teaching, 21*(5), 543–564. https://doi.org/10.1080/13540602.2014.995477

Bressler, D. M., & Bodzin, A. M. (2013). A mixed methods assessment of students' flow experiences during a mobile augmented reality science game. *Journal of Computer Assisted Learning, 29*(6), 505–517. https://doi.org/10.1111/jcal.12008

Dos Santos, L. M. (2020). Pre-service teachers' pedagogical development through the peer observation professional development programme. *South African Journal of Education, 40*(3), Article 1812. https://doi.org/10.15700/saje.v40n3a1812

Em, S., Khan, S., & Nun, N. (2023). Education system in Cambodia: A brief review from the prehistoric period to the present, and an education strategic plan for the future. *FIRE: Forum for International Research in Education, 7*(3), 141–164. https://doi.org/10.32865/fire202273320

Fisher, M. J., & Marshall, A. P. (2009). Understanding descriptive statistics. *Australian Critical Care, 22*(2), 93–97. https://doi.org/10.1016/j.aucc.2008.11.003

Fullan, M. (2007). *The new meaning of educational change* (4th ed.). Teachers College Press.

Hattie, J. (2009). *Visible learning: A synthesis of over 800 meta-analyses relating to achievement*. Routledge.

Houn, T., & Em, S. (2022). Common factors affecting Grade 12 students' speaking fluency: A survey of Cambodian high school students. *Jurnal As-Salam, 6*(1), 11–24. https://doi.org/10.37249/assalam.v6i1.360

Kagoda, A. M., & Sentongo, J. (2015). Practicing teachers' perceptions of teacher trainees: Implications for teacher education. *Universal Journal of Educational Research, 3*(2), 148–153. https://doi.org/10.13189/ujer.2015.030211

Kushairi, A., Loh, S. K., Azman, I., Hishamuddin, E., Ong-Abdullah, M., Izuddin, Z. B. M. N., Razmah, G., Sundram, S., & Parveez, G. K. A. (2018). Oil palm economic performance in Malaysia and R&D progress in 2017. *Journal of Oil Palm Research, 30*(2), 163–195. https://doi.org/10.21894/jopr.2018.0030

Lei, S. A., & Yin, D. (2019). Evaluating benefits and drawbacks of internships: Perspectives of college students. *College Student Journal, 53*(2), 181–189.

Lobo, J. (2022). Pre-service teachers' evaluation of the student internship program: Basis for design improvement. *Journal for Educators, Teachers and Trainers, 13*(5), 48–56. https://doi.org/10.47750/jett.2022.13.05.005

Margetts, K., & Ure, C. (2007). *Supporting and empowering pre-service teachers in their transition to independent teacher* [Conference paper]. Australian Association for Research in Education International Educational Research Conference, Fremantle, Western Australia.

Marzano, R. J., Marzano, J. S., & Pickering, D. J. (2003). *Classroom management that works: Research-based strategies for every teacher*. ASCD.

MoEYS. (2010). *Teacher professional standards*.

MoEYS. (2021). *Teacher career path framework*.

MoEYS. (2024). *Teacher policy action plan 2024–2030*. https://moeys.gov.kh/storage/uploads/documents//6699e393cbbd6.pdf

Navarro Rodríguez, M., García López, R. I., & Edel Navarro, R. (2019). Perceptions of students about teaching knowledge and effective teachers at the high school level. In *INTED2019 proceedings* (pp. 1648–1657). IATED. https://doi.org/10.21125/inted.2019.0486

Onwuegbuzie, A. J., Bustamante, R. M., & Nelson, J. A. (2010). Mixed research as a tool for developing quantitative instruments. *Journal of Mixed Methods Research, 4*(1), 56–78. https://doi.org/10.1177/1558689809355805

Orb, A., Eisenhauer, L., & Wynaden, D. (2001). Ethics in qualitative research. *Journal of Nursing Scholarship, 33*(1), 93–96. https://doi.org/10.1111/j.1547-5069.2001.00093.x

Organization for Economic Co-operation and Development. (2019). *Teachers and school leaders as lifelong learners: TALIS 2018 results* (Vol. 1). OECD Publishing. https://doi.org/10.1787/1d0bc92a-en

Panda, S., & Nayak, R. N. (2014). Problems of student teachers during internship programmes: Issues and concerns. *BEST: International Journal of Humanities, Arts, Medicine and Sciences, 2*(8), 61–66.

Parveen, S., & Mirza, N. (2012). Internship program in education: Effectiveness, problems and prospects. *International Journal of Learning and Development, 2*(1), 487–498. https://doi.org/10.5296/ijld.v2i1.1471

Schambach, T. P., & Dirks, J. (2002). Student perceptions of internship experiences. In *Proceedings of the 17th Annual Conference of the International Academy for Information Management* (pp. 1–8). https://files.eric.ed.gov/fulltext/ED481733.pdf

Schön, D. A. (1983). *The reflective practitioner: How professionals think in action*. Basic Books.

Sharzadin, A., Utebayev, I., Syzdykova, N., Shaushekova, B., Kossybayeva, U., Mukhatayev, A., & Kurymbayev, S. (2019). Teaching internship in mathematics teacher education. *International Journal of Emerging Technologies in Learning, 14*(12), 57–70. https://doi.org/10.3991/ijet.v14i12.10617

Shulman, L. S. (1986). Those who understand: Knowledge growth in teaching. *Educational Researcher, 15*(2), 4–14. https://doi.org/10.3102/0013189X015002004

Smith, J., & Souviney, R. J. (1997). The internship in teacher education. *Teacher Education Quarterly, 24*(2), 5–19.

Sok, S., Chhinh, N., Hor, S., & Nguonphan, P. (2021). Climate change impacts on rice cultivation: A comparative study of the Tonle Sap and Mekong River. *Sustainability, 13*(16), Article 8979. https://doi.org/10.3390/su13168979

Sørensen, H. T., Sabroe, S., & Olsen, J. (1996). A framework for evaluation of secondary data sources for epidemiological research. *International Journal of Epidemiology, 25*(2), 435–442. https://doi.org/10.1093/ije/25.2.435

Terry, G., Hayfield, N., Clarke, V., & Braun, V. (2017). Thematic analysis. In C. Willig and W. Stainton Rogers (Eds.), *The SAGE handbook of qualitative research in psychology* (2nd ed., pp. 17–37). SAGE Publications.

Turman, P. D., & Schrodt, P. (2006). Student perceptions of teacher power as a function of perceived teacher confirmation. *Communication Education, 55*(3), 265–279. https://doi.org/10.1080/03634520600702570

Umar, A. M., & Wachiko, B. (2021). Tara Yamane (1967), Taro Yamane method for sample-size calculation: The survey causes of mathematics anxiety among secondary school students in Minna metropolis. *Journal of the Mathematical Association of Nigeria, 46*(1), 188.

UNESCO. (2015). *Education 2030: Incheon Declaration and Framework for Action for the implementation of Sustainable Development Goal 4*.

Vygotsky, L. S. (1978). *Mind in society: The development of higher psychological processes*. Harvard University Press.

Wasonga, T. A., & Murphy, J. F. (2006). Learning from tacit knowledge: The impact of the internship. *International Journal of Educational Management, 20*(2), 153–163. https://doi.org/10.1108/09513540610646136